## ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ១៤-៦-២០១៤ | -ព្រះរាជក្រម នស/រកម/០៦១៤/០១៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីគយ | ៥៨៦៤ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៦ ស្តីពី ការដាក់ឯកឧត្តម **ថៃ នរៈសត្យា** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥៩២៩ |
| ០៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៧ ស្តីពី ការដាក់លោកជំទាវ **ឈូត ឈួចឡូ** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទេសចរណ៍ | ៥៩៣០ |
| ០៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្តម **អ៊ុំ សុថា** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៥ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្នុងករណីចាំបាច់ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៥៩៣១ |
| ០៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឯកឧត្តម **អ៊ឹម គឹមលន** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្នុងករណីចាំបាច់ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥៩៣២ |
| ០៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៩០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប | ៥៩៣៣ |
| ០៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៩១ ស្តីពី ការតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនឯកឧត្តម **ហេង សុខឃៀង** ពីឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅអង្គភាពប្រឆាំងអំពើពុករលួយ | ៥៩៣៤ |

០៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៩២ ស្ដីពី ការផ្ទេរបញ្ចូលលោក ម៉ា ទិចិត្រ ពី ឋានន្តរស័ក្តិវរសេនីយ៍ត្រី នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាក្រសួងមហាផ្ទៃ ទៅក្នុង ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១០ នៃ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួង មហាផ្ទៃ ៥៩៣៥

០៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៩៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងបណ្ឌិត ចំនួន ០២ រូប ៥៩៣៦

០៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៩៤ ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាកីឡាកម្ពុជា ចំនួន ១៩ រូប ៥៩៣៧

០៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៩៥ ស្ដីពី ការតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនមន្ត្រីរាជការ ចំនួន ០២ រូប ៥៩៣៩

## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៣-៦-២០១៤ -អនុក្រឹត្យលេខ ២០៤ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៥៩៤១

២០-៦-២០១៤ -អនុក្រឹត្យលេខ ២០៥ អនក្រ.បក ស្ដីពី ការផ្ដល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ ៥៩៤៣

២៤-៦-២០១៤ -អនុក្រឹត្យលេខ ២០៦ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៥៩៤៥

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៩៤៧

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៩៥៧

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៩៦០

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៩០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៩៦១

២៧-៥-២០១៤ -អនុក្រឹត្យលេខ ៥៩១ អនក្រ.តត ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជារី " អាណត្តិទី ៥ ៥៩៦៧

២៧-៥-២០១៤ -អនុក្រឹត្យលេខ ៥៩២ អនក្រ.តត ស្ដីពី ការតែងតាំងអគ្គនាយកនៃក្រុមហ៊ុនធានារ៉ាប់រង បន្តកម្ពុជា " កម្ពុជារី " អាណត្តិទី ៥ ៥៩៦៩

## គ

## III. ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០២-៦-២០១៤ -ប្រកាសលេខ ៦២៦ សហវ.ប្រក ស្ដីពី ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយ និងរដ្ឋាករខេត្តត្បូងឃ្មុំ ៥៩៧១

៣០-៦-២០១៤ -ប្រកាសលេខ ៦៦៤ សហវ.ប្រក ស្ដីពី ការដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋ លើមុខទំនិញមួយចំនួន ៥៩៧៤


### ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម


០៨-៥-២០១៤ -ប្រកាសលេខ ៣៩៣ ឧស.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ជីធាន (ខេមបូឌា) បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៥៩៧៦

២៧-៥-២០១៤ -ប្រកាសលេខ ៤៣៩ ឧស.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.ស៊ី.អេស សេរីនគរ បង្កើតរោងចក្រផលិត សម្ភារៈវេចខ្ចប់ (ពីប្លាស្ទិក), សម្ភារៈវេជ្ជសាស្ត្រ (ពីប្លាស្ទិក) ៥៩៨០

២៧-៥-២០១៤ -ប្រកាសលេខ ៤៤០ ឧស.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វូ គៀត ព្រីនធីង បង្កើតរោងចក្រផលិត សម្លៀកបំពាក់ (បោះពុម្ព) ៥៩៨៤

# ព្រះរាជក្រម

នស/រកម/០៦១៤/០១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

រកម.០៦១៤.០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខៈ ៧៦៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# កិច្ចព្រមព្រៀងអាស៊ានស្តីពីគយ

## បុព្វកថា

រដ្ឋាភិបាលនៃប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃប្រជាជាតិអាស៊ីអគ្នេយ៍ (ដែលហៅថា " បណ្តាប្រទេសសមាជិក " ឬតែមួយហៅថា "ប្រទេសសមាជិក")

**ដោយរំលឹកឡើងវិញ** នូវសេចក្តីសម្រេចរបស់ប្រមុខដឹកនាំ ដើម្បីបង្កើតសហគមន៍អាស៊ានមានសសរស្តម្ភបីគឺ សហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASCC) ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍ចាអាមហ៊ួហ៊ីន (The Cha-am Hua Hin Declaration) ស្តីពីផែនទីបង្ហាញផ្លូវសហគមន៍អាស៊ាន(២០០៩-២០១៥) ដែលបានចុះហត្ថលេខានាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងនៅក្នុងធម្មនុញ្ញអាស៊ាន ដែលបានចុះហត្ថលេខានៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសឹង្ហបុរី

**ប្តេជ្ញា** ធ្វើឲ្យសម្រេចគោលដៅក្នុងការបង្កើតអាស៊ានជាទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយដែលមានចរិកលក្ខណៈនៃសេរីកម្មទំនិញ សេវា វិនិយោគ ពលកម្មជំនាញ និងធ្វើឲ្យមានសេរីកម្មជាងមុននៃលំហូរទុន ដូចមានគ្រោងទុកដោយធម្មនុញ្ញអាស៊ាន និងប្រកាសស្តីពីផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលបានចុះហត្ថលេខាដោយប្រមុខអាស៊ាន នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសឹង្ហបុរី

**ដោយទទួលស្គាល់** សមិទ្ធិផលសំខាន់ៗ និងការរួមចំណែកទៅនឹងបណ្តាកិច្ចព្រមព្រៀង និងឧបករណ៍សេដ្ឋកិច្ចអាស៊ានដែលមានស្រាប់នៅក្នុងវិស័យផ្សេងៗ ក្នុងការសម្រួលលំហូរទំនិញដោយសេរីនៅក្នុងតំបន់ រួមទាំងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន (២០០៩) កិច្ចព្រមព្រៀងអាស៊ានស្តីពីគយ(១៩៩៧) កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការរៀបចំការទទួលស្គាល់គ្នាទៅវិញទៅមក (១៩៩៨) កិច្ចព្រមព្រៀងក្របខ័ណ្ឌ អ៊ី-អាស៊ាន (២០០០) ពិធីសារស្តីពីការអនុវត្តនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់អាស៊ាន (២០០៣) ព្រមទាំងវិសោធនកម្មរបស់វា កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសម្រាប់សមាហរណកម្មវិស័យអាទិភាព(២០០៤) កិច្ចព្រមព្រៀងស្តីពីការបង្កើតនិងអនុវត្តបញ្ជរតែមួយអាស៊ាន(២០០៥) និងពិធីសារស្តីពីបង្កើតនិងអនុវត្តបញ្ជរតែមួយអាស៊ាន (២០០៦)

**ដោយទទួលស្គាល់** សន្ទុះនៃការប្រើប្រាស់ អ៊ី-ពាណិជ្ជកម្ម និងព័ត៌មានវិទ្យា និងបច្ចេកវិទ្យាទូរគមនាគមន៍ ដើម្បីដំណើរការព័ត៌មានពាក់ព័ន្ធពាណិជ្ជកម្ម និងគយ សម្រាប់ការបំពេញបែបបទគយ និងការបញ្ចេញទំនិញ និងមធ្យោបាយដឹកជញ្ជូន ក្នុងគោលបំណងសម្រេចឲ្យបាននូវការប្រកួតប្រជែងសេដ្ឋកិច្ច និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដោយអាជ្ញាធរគយនៃបណ្តាប្រទេសសមាជិក

**ដោយទទួលស្គាល់** តម្រូវការនៃការធ្វើឲ្យប្រសើរឡើង និងសុខដុមនីយកម្មនីតិវិធីគយ ដើម្បីគាំទ្រដល់ការបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយអាស៊ាន

**ដោយទទួលស្គាល់** អាជ្ញាធរគយដើរតួនាទីជាអ្នកសម្រួលពាណិជ្ជកម្ម ដើម្បីគាំទ្រដល់ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន និងជាអ្នកការពារសហគមន៍អាស៊ាន ក្នុងភាពជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនានា

**ដោយប្រាថ្នា** បង្កើតក្របខ័ណ្ឌគតិយុត្តិគ្រប់ជ្រុងជ្រោយអាស៊ានស្តីពីការងារពាក់ព័ន្ធគយ ដែលមានសមត្ថភាពអនុវត្តវិធានការ និងសកម្មភាពជាក់លាក់ ដើម្បីសម្រួលលំហូរទំនិញដោយសេរី និងមធ្យោបាយដឹកជញ្ជូនក្នុងតំបន់ និងដើម្បីការពារសុខមាលភាពសហគមន៍អាស៊ាន

**ដោយប្រាថ្នា** ថែមទៀត ការកាត់បន្ថយរបាំង និងទំនាក់ទំនងសេដ្ឋកិច្ចស៊ីជម្រៅក្នុងចំណោមបណ្តាប្រទេសសមាជិក ការកាត់បន្ថយចំណាយអាជីវកម្ម ការបង្កើនពាណិជ្ជកម្ម វិនិយោគ និង

សេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ការបង្កើតទីផ្សារទូលាយជាមួយកាលានុវត្តភាព និងទំហំសេដ្ឋកិច្ចដ៏ធំសម្រាប់ពាណិជ្ជកម្មរបស់បណ្តាប្រទេសសមាជិក និងរក្សាបានជាតំបន់វិនិយោគប្រកបដោយការប្រកួតប្រជែង

**ដោយទទួលស្គាល់** កម្រិតខុសគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរវាង និងក្នុងចំណោមបណ្តាប្រទេសសមាជិក និងសេចក្តីត្រូវការដើម្បីបំបាត់គម្លាតអភិវឌ្ឍន៍ និងសម្រួលការចូលរួមកាន់តែច្រើនឡើងរបស់បណ្តាប្រទេសសមាជិក ជាពិសេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានតាមរយៈការផ្តល់នូវភាពទន់ភ្លន់ និងសហប្រតិបត្តិការបច្ចេកទេស និងអភិវឌ្ឍន៍

**ដោយទទួលស្គាល់ថា** តួនាទីសំខាន់ និងការរួមចំណែករបស់វិស័យពាណិជ្ជកម្មក្នុងការបង្កើនពាណិជ្ជកម្ម និងវិនិយោគក្នុងចំណោមបណ្តាប្រទេសសមាជិក និងតម្រូវការជម្រុញនិងសម្រួលការចូលរួមរបស់ពួកគេតាមរយៈសមាគមពាណិជ្ជកម្មអាស៊ាននានា ក្នុងការសម្រេចបានការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន និង

**ដោយទទួលស្គាល់** តួនាទីនៃកិច្ចព្រមព្រៀងគយតំបន់ជាកាតាលីករសម្រាប់ទំនើបកម្មបច្ចេកទេសគយនិងការផ្តល់សេវាសាធារណៈយ៉ាងល្អដល់សហគមន៍អាស៊ាន ទន្ទឹមនឹងការជម្រុញសេរីកម្មពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក និងការសម្រួលពាណិជ្ជកម្ម និងដូចជាមូលដ្ឋានគ្រឹះក្នុងក្របខ័ណ្ឌនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី

បានព្រមព្រៀង ដូចតទៅនេះ ៖

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១.-គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺ ៖

ក- លើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រដើម្បីសម្រេចបានការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន និងការការពារសហគមន៍អាស៊ាន។

ខ- ធ្វើសាមញ្ញ ធ្វើសុខដុម និងធ្វើទំនើបកម្មនីតិវិធីគយ បែបបទគយ និងការអនុវត្តការត្រួតពិនិត្យគយ ការគ្រប់គ្រងការធ្វើចរាចរ និងលំហូរទំនិញ និងមធ្យោបាយដឹកជញ្ជូនសម្រាប់

ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន អនុលោមតាមបទដ្ឋានអន្តរជាតិ ។

គ- សម្រួលពាណិជ្ជកម្មអន្តរជាតិ និងចរាចរទំនិញ និងមធ្យោបាយដឹកជញ្ជូនក្នុងចំណោមបណ្តាប្រទេសសមាជិក ស្របតាមការកំណត់ដោយសង្គតិភាព និងឯកភាពនៃតម្លៃគិតពន្ធគយ ដើមកំណើតទំនិញ និងចំណាត់ថ្នាក់ទំនិញ។

ឃ- ផ្តល់នូវក្របខ័ណ្ឌរួម ដើម្បីធ្វើនិយតកម្មប្រតិបត្តិការគយ និងអន្តរាគមន៍នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ង- ពន្លឿនការធ្វើបែបបទគយ និងការបញ្ចេញទំនិញ និងមធ្យោបាយដឹកជញ្ជូន តាមនីតិវិធី និងទម្រង់ការគយប្រកបដោយប្រសិទ្ធភាព អនុលោមតាមអនុសញ្ញា កិច្ចព្រមព្រៀងបមាណីយ និងការអនុវត្តល្អជាអន្តរជាតិ ដោយទុកពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យគយ ។

ច- អនុម័តយកបទដ្ឋានអន្តរជាតិសម្រាប់ការពារខ្សែចង្វាក់ផ្គត់ផ្គង់ ដូចជា ក្របខ័ណ្ឌបមាណីយសន្តិសុខនិងសម្រួលពាណិជ្ជកម្មពិភពលោករបស់អង្គការគយពិភពលោក (SAFE)។

ឆ- ធានាតម្លាភាព សង្គតិភាព និងទស្សនទ្វភាព ដើម្បីអនុវត្តច្បាប់គយរបស់បណ្តាប្រទេសសមាជិក ក្នុងគោលបំណងបន្តលើកកម្ពស់អនុលោមភាពច្បាប់ស្តីពីគយ។ និង

ជ- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមករបស់អាជ្ញាធរគយបណ្តាប្រទេសសមាជិក ស្តីពីគយនិងការងារពាក់ព័ន្ធគយ រួមទាំងការទប់ស្កាត់ និងការបង្ក្រាបរាល់ទម្រង់នៃការគេចពន្ធ និងបទល្មើសគយ។

## មាត្រា២.- គោលការណ៍

បណ្តាប្រទេសសមាជិក នឹងត្រូវបង្ហាញតាមគោលការណ៍ដូចខាងក្រោម៖

ក- សង្គតិភាព៖ បណ្តាប្រទេសសមាជិកត្រូវធានាបន្តការអនុវត្តច្បាប់ស្តីពីគយ និងបែបបទរដ្ឋបាលប្រកបដោយសង្គតិភាព ជាមួយប្រទេសសមាជិកនីមួយៗ ។

ខ- ប្រសិទ្ធភាព៖បណ្តាប្រទេសសមាជិកត្រូវធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនូវរបបគយ នីតិវិធី និងការអនុវត្ត ក្នុងការជម្រុញលំហូរទំនិញដោយសេរី និងមធ្យោបាយដឹកជញ្ជូនក្នុងអាស៊ាន តាមមធ្យោបាយប្រសើរបំផុត។

គ- សាមញ្ញកម្ម៖ បណ្តាប្រទេសសមាជិកត្រូវធានាបន្តធ្វើសាមញ្ញកម្មនីតិវិធី ទម្រង់ការគយ និងការអនុវត្ត ដោយអនុលោមតាមអនុសញ្ញាពាក់ព័ន្ធ និងការអនុវត្តល្អជាអន្តរជាតិ។

ឃ- តម្លាភាព៖ បណ្តាប្រទេសសមាជិកត្រូវផ្សព្វផ្សាយច្បាប់និងនីតិវិធីរដ្ឋបាលពាក់ព័ន្ធការងារគយដល់សាធារណៈជនឲ្យបានទាន់ពេលវេលា លើកលែងតែសេចក្តីណែនាំសម្រាប់ប្រតិបត្តិការផ្ទៃក្នុង។

ង- ពិគ្រោះយោបល់៖ បណ្តាប្រទេសសមាជិក ត្រូវខិតខំពិគ្រោះយោបល់ជាមួយផ្នែកឯកជន និងដៃគូពាក់ព័ន្ធផ្សេងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

ច- ការប្តឹងឧទ្ធរណ៍៖ បណ្តាប្រទេសសមាជិកត្រូវធានាឲ្យមានយន្តការសមស្របក្នុងការពិនិត្យឡើងវិញនូវសេចក្តីសម្រេចគយក្នុងរយៈពេលកំណត់មួយ។

ឆ- កិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយ៖ បណ្តាប្រទេសសមាជិកត្រូវខិតខំផ្តល់កិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយជាអតិបរិមា រវាងអាជ្ញាធរគយរបស់បណ្តាប្រទេសសមាជិក។

## មាត្រា៣.- វិសាលភាពនៃកិច្ចព្រមព្រៀង

១- បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះទំនិញដែលបាននាំចូល នាំចេញ ដឹកជញ្ជូនឆ្លងកាត់ ឬផ្ទេរមធ្យោបាយដឹកជញ្ជូន ដោយឆ្លងកាត់ដែនដីរបស់បណ្តាប្រទេសសមាជិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិក។

២- ប្រទេសសមាជិក មិនត្រូវបានរារាំងក្នុងការផ្តល់កិច្ចជួយសម្រួលលើសពីអ្វីដែលចែងក្នុងកិច្ចព្រមព្រៀងនេះ ។ បណ្តាប្រទេសសមាជិក ត្រូវខិតខំផ្តល់កិច្ចជួយសម្រួលឲ្យបានច្រើនតាមដែលអាចធ្វើបាន។

## មាត្រា៤.- ការអនុវត្ត

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តឲ្យដូចគ្នាទូទាំងដែនដីនៃបណ្តាប្រទេសសមាជិក។

## មាត្រា៥.- និយមន័យ

លើកលែងតែបរិបទតម្រូវផ្សេងពីនេះ សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ៖

ក- **ការប្តឹងឧទ្ធរណ៍** គឺជាច្បាប់មួយ ដែលតាមរយៈនោះបុគ្គលម្នាក់ដែលទទួលផលប៉ះពាល់ដោយសារសេចក្តីសម្រេច ឬការខកខានផ្នែកនីតិវិធីរបស់គយ ហើយដែលគិតថាខ្លួនជាអ្នករងគ្រោះ អាចស្វែងរកការកែប្រែសេចក្តីសម្រេចនោះចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។

**ខ- ការត្រួតពិនិត្យដោយឈរលើមូលដ្ឋានសវនកម្ម** គឺជាវិធានការដែលអាជ្ញាធរគយជ្រើសរើសក្នុងការបញ្ជាក់ពីភាពត្រឹមត្រូវ និងស្របច្បាប់នៃប្រតិវេទន៍ តាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធដូចជា សៀវភៅ បញ្ជី កំណត់ត្រា ប្រព័ន្ធធុរកិច្ច និងទិន្នន័យពាណិជ្ជកម្មដែលគ្រប់គ្រងដោយបុគ្គលពាក់ព័ន្ធ។

**គ- អាជ្ញាធរគយ** គឺជាអាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវក្រោមច្បាប់នៃប្រទេសសមាជិកសម្រាប់អនុវត្តច្បាប់គយ។

**ឃ- ការបំពេញបែបបទបញ្ចេញទំនិញពីគយ** គឺជាការបំពេញនូវទម្រង់ការគយចាំបាច់នានា ដើម្បីទទួលបានការអនុញ្ញាតឲ្យទំនិញអាចដាក់ឲ្យប្រើប្រាស់បានក្នុងប្រទេស អាចឲ្យនាំចេញ ឬដាក់ក្រោមរបបគយមួយផ្សេងទៀតបាន។

**ង- ការត្រួតពិនិត្យគយ** គឺជាវិធានការដែលកំណត់ដោយអាជ្ញាធរគយដើម្បីធានានូវអនុលោមភាពជាមួយច្បាប់គយរបស់បណ្តាប្រទេសសមាជិក។

**ច- ពន្ធគយ** គឺជាពន្ធដែលដាក់ក្នុងតារាងពន្ធគយលើទំនិញដែលធ្វើចរាចរចេញឬក៏ចូលដែនគយ។

**ឆ- ទម្រង់ការគយ** គឺជាប្រតិបត្តិការដែលត្រូវអនុវត្តដោយបុគ្គលពាក់ព័ន្ធ និងដោយអាជ្ញាធរគយក្នុងគោលបំណងគោរពតាមច្បាប់គយ។

**ជ- ច្បាប់គយ** គឺជាបញ្ញត្តិនៃលក្ខន្តិកៈ និងបទដ្ឋាននានាដែលទាក់ទិននឹងការនាំចេញ នាំចូល ចរាចរ និងសន្និធិទំនិញ រដ្ឋបាល និងការអនុវត្តច្បាប់ និងបទដ្ឋាននានាដែលរៀបចំដោយអាជ្ញាធរគយ ដែលក្រោមអំណាចផ្លូវច្បាប់គយ។

**ឈ- ការិយាល័យគយ** គឺជាអង្គភាពរដ្ឋបាលគយដែលមានសមត្ថកិច្ចគ្រប់គ្រងត្រួតពិនិត្យទម្រង់ការគយ អគារ ឬទីតាំងផ្សេងៗដែលទទួលការអនុញ្ញាតសម្រាប់គោលបំណងនេះ ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ញ- នីតិវិធីគយ** គឺជាប្រព្រឹត្តកម្មដែលអនុវត្តដោយអាជ្ញាធរគយរបស់ប្រទេសសមាជិកចំពោះមុខទំនិញដែលជាកម្មវត្ថុនៃការអនុវត្តច្បាប់គយ។

**ដ- សេចក្តីសម្រេច** គឺជាអំពើរបស់បុគ្គលដែលអាជ្ញាធរគយវិនិច្ឆ័យលើបញ្ហាមួយដោយអនុលោមតាមច្បាប់គយ។

**ឋ- ប្រតិវេទករ** គឺជាជាបុគ្គលដែលធ្វើការប្រកាសដល់គយក្នុងនាមខ្លួនផ្ទាល់ ឬក្នុងនាមអ្នកដទៃ។

**ឌ- ការសងប្រាក់** គឺជាទឹកប្រាក់ពន្ធនិងអាករនាំចូល ត្រូវបានបង់សងទៅវិញក្រោមនីតិវិធីនៃការសងប្រាក់។

**ឈ- ការត្រួតពិនិត្យទំនិញ** គឺជាការត្រួតពិនិត្យរូបវន្តលើទំនិញដោយអាជ្ញាធរគយ ដើម្បីឲ្យជាក់ច្បាស់អំពី យថាប្រភេទ ដើមកំណើតទំនិញ លក្ខខណ្ឌ បរិមាណ និងតម្លៃទំនិញ ថាមានភាពស្របគ្នាជាមួយនឹងការប្រកាសក្នុងប្រតិវេទន៍ទំនិញ។

**ណ- ប្រតិវេទន៍ទំនិញ** គឺជាសេចក្តីរាយការណ៍ ធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយអាជ្ញាធរគយ ដែលបុគ្គលសាមីបង្ហាញពីនីតិវិធីគយដែលនឹងត្រូវអនុវត្តចំពោះទំនិញ និងការកំណត់ជាក់លាក់នានាដែលអាជ្ញាធរគយតម្រូវឲ្យមានការប្រកាស ដើម្បីអនុវត្តតាមនីតិវិធីនេះ។

**ត- មធ្យោបាយដឹកជញ្ជូន** គឺជាយានយន្តដឹកទំនិញតាមផ្លូវគោក ទូររថភ្លើង ទូក ឬកប៉ាល់ដឹកទំនិញតាមទន្លេ និងសមុទ្រ និងយន្តហោះ។

**ថ- ការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយ** គឺជាសកម្មភាពដែលធ្វើឡើងដោយរដ្ឋបាលគយបណ្តាប្រទេសសមាជិកក្នុងនាម ឬក្នុងកិច្ចសហការជាមួយប្រទេសសមាជិក ដើម្បីអនុវត្តច្បាប់គយឲ្យមានប្រសិទ្ធភាព។

**ទ- បុគ្គល** គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល លើកលែងតែមានបរិបទដោយឡែក។

**ធ- ការបញ្ចេញទំនិញពីគយ** គឺជាសកម្មភាពដែលធ្វើឡើងដោយអាជ្ញាធរគយ ដើម្បីអនុញ្ញាតឲ្យទំនិញដែលស្ថិតនៅក្រោមការធ្វើបែបបទបញ្ចេញទំនិញសម្រាប់យកមកប្រើប្រាស់ដោយបុគ្គលដែលពាក់ព័ន្ធ។

**ន- ការទូទាត់សងវិញ** គឺជាការសងប្រាក់វិញទាំងអស់ ឬដោយផ្នែកចំពោះប្រាក់ពន្ធ និងអាករដែលបានបង់សម្រាប់ទំនិញ។

**ប- ឯកសារគាំទ្រ** គឺជាឯកសារយោងសម្រាប់គាំទ្រប្រតិវេទន៍ទំនិញ ដែលអាជ្ញាធរគយប្រទេសសមាជិកយល់ថាចាំបាច់សម្រាប់អនុញ្ញាតឲ្យមានការត្រួតពិនិត្យប្រតិបត្តិការនិងធានាថាពល់ឯកសារចាំបាច់ត្រូវឲ្យមានអនុលោមភាពតាមច្បាប់គយ។

**ផ- ប្រវេសន៍កាលិក** គឺជានីតិវិធីគយដែលអនុញ្ញាតឲ្យទំនិញនាំចូលបានក្នុងដែនគយក្រោមលក្ខខណ្ឌរួចផុតពីការបង់ពន្ធនិងអាករទាំងស្រុង ឬភាគខ្លះ ។ ទំនិញទាំងនោះត្រូវបាននាំចូលក្នុងគោលបំណងច្បាស់លាស់ ហើយត្រូវនាំចេញទៅវិញក្នុងកម្រិតពេលវេលាជាក់លាក់មួយ និងមិនធ្វើការកែច្នៃ ឬផ្លាស់ប្តូរ លើកលែងតែការរំលស់ជាធម្មតាតាមការប្រើប្រាស់។

## ជំពូកទី២

## នីតិវិធីគយ និង ទម្រង់ការគយ

## មាត្រា៦.- នីតិវិធីគយ

១- បណ្តាប្រទេសសមាជិក ត្រូវធានាពីតម្លាភាពនៃនីតិវិធីគយ និងការអនុវត្តប្រកបដោយសង្គតិភាព និងទស្សលទ្ធភាព ក្នុងការសម្រួលពាណិជ្ជកម្ម និងវិនិយោគទុននៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

២- នីតិវិធីគយ និងការអនុវត្តរបស់បណ្តាប្រទេសសមាជិក ត្រូវតែមានសង្គតិភាពដោយកម្រិតណាមួយ ជាមួយនឹងអនុសញ្ញា លិខិតុបករណ៍ បមាណីយ និងការអនុវត្តល្អជាអន្តរជាតិរបស់អង្គការគយពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀត។

៣- បណ្តាប្រទេសសមាជិក ត្រូវពិនិត្យឡើងវិញជាប្រចាំនូវនីតិវិធីគយ និងការអនុវត្តក្នុងគោលបំណងធ្វើសាមញ្ញកម្ម សុខដុមកម្ម និងទំនើបកម្មថែមទៀតលើនីតិវិធី និងការអនុវត្តដើម្បីសម្រួលពាណិជ្ជកម្ម ប៉ុន្តែត្រូវរក្សាឲ្យបាននូវអនុលោមភាពជាមួយច្បាប់ស្តីពីគយ។

## មាត្រា៧.- ការត្រួតពិនិត្យគយ

១- គ្រប់ទំនិញ រួមទាំងមធ្យោបាយដឹកជញ្ជូនដែលចូលមកក្នុង ឬចេញពីដែនគយរបស់បណ្តាប្រទេសសមាជិក ទោះជាជាប់ពន្ធនិងអាករ ឬត្រូវបានលើកលែងពន្ធនិងអាករ គឺជាកម្មវត្ថុនៃការត្រួតពិនិត្យគយ។

២- អាជ្ញាធរគយប្រទេសសមាជិក ត្រូវអនុវត្តការត្រួតពិនិត្យដែលយល់ថាចាំបាច់ ដើម្បីធានាអនុលោមភាព និងការអនុវត្តច្បាប់គយឲ្យបានត្រឹមត្រូវ និងច្បាប់ផ្សេងទៀត ដែលគ្រប់គ្រងការនាំចូល ការនាំចេញ ការដឹកជញ្ជូនឆ្លងកាត់ ការផ្ទេរមធ្យោបាយដឹកជញ្ជូន សន្និធិ និងការដាក់ឲ្យប្រើប្រាស់ក្នុងប្រទេសនៃទំនិញ រួមទាំងចរាចរកញ្ចប់ប្រៃសណីយ៍ក្នុងដែនដីនៃប្រទេសសមាជិកពាក់ព័ន្ធ។

៣- បណ្តាប្រទេសសមាជិកត្រូវធានាថា ការត្រួតពិនិត្យគយត្រូវធ្វើឡើងក្នុងកម្រិតត្រឹមតែធានានូវអនុលោមភាពជាមួយច្បាប់គយរបស់ប្រទេសសមាជិក។

៤- ការត្រួតពិនិត្យគយ ក្នុងចំណោមការត្រួតពិនិត្យផ្សេងទៀត រួមមាន ការត្រួតពិនិត្យចរាចរទំនិញ ការត្រួតពិនិត្យទំនិញ ការដកយកសំណាកគំរូ ការផ្ទៀងផ្ទាត់ទិន្នន័យប្រតិវេទន៍ និងភាពត្រឹមត្រូវនៃឯកសារ ការពិនិត្យមើលគណនេយ្យ សៀវភៅបញ្ជី និងកំណត់ត្រារបស់ប្រតិបត្តិករសេដ្ឋកិច្ច ការធ្វើអធិការកិច្ចលើមធ្យោបាយដឹកជញ្ជូន ឥវ៉ាន់ និងទំនិញផ្សេងទៀតដែលកាន់យួរដោយបុគ្គល និងការអនុវត្តតាមតម្រូវការរបស់មន្ត្រី។

៥- ក្នុងការអនុវត្តការត្រួតពិនិត្យគយ បណ្តាប្រទេសសមាជិកត្រូវប្រើប្រាស់ការគ្រប់គ្រងហានិភ័យ និងអនុវត្តការត្រួតពិនិត្យដោយឈរលើមូលដ្ឋានសវនកម្ម ។

## មាត្រា៨.- ការត្រួតពិនិត្យទំនិញ

១- នៅពេលអាជ្ញាធរគយសម្រេចត្រួតពិនិត្យទំនិញដែលបានប្រកាស ការត្រួតពិនិត្យត្រូវធ្វើឲ្យបានលឿនតាមដែលអាចធ្វើបាន បន្ទាប់ពីប្រតិវេទន៍ទំនិញត្រូវបានចុះបញ្ជី។ អាទិភាពត្រូវផ្តល់ចំពោះការត្រួតពិនិត្យសត្វរស់ ទំនិញដែលងាយខូត និងទំនិញពាក់ព័ន្ធផ្សេងទៀតដែលអាជ្ញាធរគយចាត់ទុកថាមានលក្ខណៈបន្ទាន់។

២- ការត្រួតពិនិត្យរូបវន្តលើទំនិញ ត្រូវរួមបញ្ចូលការផ្ទៀងផ្ទាត់សុក្រឹតភាព និងភាពពេញលេញនៃព័ត៌មាន និងអនុលោមភាពតាមច្បាប់គយ ជាពិសេសពាក់ព័ន្ធនឹងយថាប្រភេទ ដើមកំណើតទំនិញ លក្ខខណ្ឌ បរិមាណ និងតម្លៃទំនិញ។

## មាត្រា៩.- ប្រតិវេទន៍ទំនិញ

១- ខ្លឹមសារប្រតិវេទន៍ទំនិញ ត្រូវបញ្ញត្តិដោយអាជ្ញាធរគយរបស់បណ្តាប្រទេសសមាជិក។

២- ខ្លឹមសារមូលដ្ឋាននៃប្រតិវេទន៍ទំនិញ ត្រូវមានប៉ារ៉ាម៉ែត្រព័ត៌មានឯកសារប្រតិវេទន៍គយអាស៊ាន។ អាជ្ញាធរគយបណ្តាប្រទេសសមាជិក អាចបញ្ញត្តិបន្ថែមប៉ារ៉ាម៉ែត្រព័ត៌មានសម្រាប់បញ្ចូលក្នុងប្រតិវេទន៍ទំនិញ។

៣- ទម្រង់ជាក្រដាសនៃប្រតិវេទន៍ទំនិញ ត្រូវអនុលោមតាមទម្រង់គន្លឹះគំនូព្រាងរបស់អង្គការសហប្រជាជាតិ និងទម្រង់វិសោធនកម្មរបស់វា។

៤- តាមដែលអាចធ្វើទៅបាន សម្រាប់កិច្ចដំណើរការបំពេញបែបបទបញ្ចេញទំនិញពីគយដោយស្វ័យប្រវត្តិកម្ម ទម្រង់ប្រតិវេទន៍ទំនិញជាអេឡិចត្រូនិកដែលបានដាក់ ត្រូវផ្អែកលើមូលដ្ឋានបទដ្ឋានអន្តរជាតិ សម្រាប់ការផ្លាស់ប្តូរព័ត៌មានអេឡិចត្រូនិក ដែលបានបង្កើតឡើងដោយអង្គការគយពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនានា ។

## មាត្រា១០.- ការប្រកាស និងចុះបញ្ជីការប្រតិវេទន៍ទំនិញ

១- តាមដែលអាចធ្វើទៅបាន ការដាក់ និងការចុះបញ្ជីការប្រតិវេទន៍ទំនិញដោយអាជ្ញាធរគយ ត្រូវអនុវត្តតាមមធ្យោបាយអេឡិចត្រូនិក។

២- បុគ្គលដែលអនុញ្ញាតដោយពេញសិទ្ធិតាមច្បាប់គយនៃបណ្តាប្រទេសសមាជិក ត្រូវដាក់ប្រតិវេទន៍ទំនិញ ជាមួយខ្លឹមសារ និងទម្រង់ដែលបញ្ញត្តិដោយអាជ្ញាធរគយពាក់ព័ន្ធ។

៣- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវអនុញ្ញាតឲ្យមានការដាក់ ការចុះបញ្ជិការ និងការត្រួតពិនិត្យប្រតិវេទន៍ទំនិញ និងឯកសារគាំទ្រ នៅការិយាល័យគយណាមួយដែលកំណត់ដោយប្រទេសសមាជិក។

៤- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំអនុញ្ញាតឲ្យមានការដាក់ និងការចុះបញ្ជិការប្រតិវេទន៍ទំនិញ មុនទំនិញមកដល់។

## មាត្រា១១.- ឯកសារគាំទ្រសម្រាប់ប្រតិវេទន៍ទំនិញ ដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ និងការបញ្ចេញទំនិញ

១- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវតម្រូវឲ្យមានតែឯកសារគាំទ្រដែលចាំបាច់ដើម្បីធានាអនុលោមភាពតាមច្បាប់គយរបស់ប្រទេសសមាជិក។

២- បណ្តាប្រទេសសមាជិក ត្រូវកំណត់ពេលវេលា និងបែបបទនៃដាក់ឯកសារគាំទ្រទៅអាជ្ញាធរគយ អនុលោមតាមច្បាប់គយ ។ ក្នុងករណីដែលឯកសារមួយចំនួនដែលមិនអាចដាក់ភ្ជាប់ជាមួយប្រតិវេទន៍ទំនិញ ដោយហេតុផលណាមួយដែលអាជ្ញាធរគយពាក់ព័ន្ធយល់ថាសមស្រប អាជ្ញាធរគយត្រូវអនុញ្ញាតឲ្យដាក់ឯកសារទាំងនោះក្នុងរយៈពេលកំណត់មួយ។

៣- បណ្តាប្រទេសសមាជិក ត្រូវអនុញ្ញាតឲ្យដាក់ឯកសារគាំទ្រតាមមធ្យោបាយអេឡិចត្រូនិកតាមដែលអាចធ្វើទៅបាន។

## មាត្រា១២.- ការប្រកាសប្រតិវេទន៍ទៅឲ្យអាជ្ញាធរគយ

១- ប្រតិវេទន៍ទំនិញ ត្រូវដាក់តាមមធ្យោបាយអេឡិចត្រូនិក តាមដែលអាចធ្វើទៅបាន។ ក្នុងករណីដែលមានចែងក្នុងច្បាប់គយ អាជ្ញាធរគយបណ្តាប្រទេសសមាជិក អាចទទួលយកប្រតិវេទន៍ទំនិញជាទម្រង់ក្រដាស ឬជាទម្រង់ផ្ទាល់មាត់ ឬជាទម្រង់ផ្សេងទៀត។

២- អាជ្ញាធរគយប្រទេសសមាជិក អាចពិចារណាទទួលយកឯកសារ ឬទិន្នន័យពាណិជ្ជកម្មដែលផ្ទុកក្នុងប្រព័ន្ធទិន្នន័យរបស់ពាណិជ្ជករជំនួសឲ្យប្រតិវេទន៍ទំនិញ ក្នុងគោលបំណងសម្រួលពាណិជ្ជកម្ម ក្នុងករណីដែលអាជ្ញាធរគយអាចចូលទៅដល់ព័ត៌មាននិងតម្រូវការទាំងនោះ សម្រាប់ជាការចាំបាច់នៃការផ្លាស់ប្តូរព័ត៌មានជាមួយការិយាល័យគយដែលត្រូវការ។

## មាត្រា១៣.- បុគ្គលប្រកាសប្រតិវេទន៍ទំនិញ

១- ប្រតិវេទន៍ទំនិញ អាចប្រកាសដោយបុគ្គលដែលទទួលការអនុញ្ញាតពេញសិទ្ធិតាមច្បាប់គយនៃបណ្តាប្រទេសសមាជិក និងជាបុគ្គលមានលទ្ធភាពបង្ហាញ ឬរៀបចំគ្រប់ឯកសារដែលមានស្រាប់ ដែលជាតម្រូវការស្របទៅតាមការអនុវត្តច្បាប់គយ។ ក្នុងករណីដែលមានការទទួលស្គាល់ថា ប្រតិវេទន៍ទំនិញតម្រូវបំពេញកាតព្វកិច្ចដោយឡែកលើបុគ្គលជាក់លាក់ កាតព្វកិច្ចទាំងនោះ ត្រូវបំពេញដោយបុគ្គលនោះ ឬតំណាងរបស់ខ្លួន។

២- ប្រតិវេទករ ត្រូវបង្កើតក្នុងដែនដីនៃប្រទេសសមាជិក ជាទីដែលប្រតិវេទន៍ទំនិញត្រូវដាក់។ ទោះបីជាយ៉ាងនេះក្តី ក្នុងកាលៈទេសៈពិសេស អាជ្ញាធរគយអាចទទួលយកប្រតិវេទករដែលបង្កើតនៅក្រៅដែនដីនៃប្រទេសសមាជិកពាក់ព័ន្ធ ប៉ុន្តែជាកម្មវត្ថុនៃអនុលោមភាពច្បាប់គយរបស់ខ្លួន។

## មាត្រា១៤.- សាមញ្ញកម្មប្រតិវេទន៍ទំនិញ

១- អាជ្ញាធរគយប្រទេសសមាជិក អាចអនុញ្ញាតឲ្យបុគ្គលទាំងឡាយ ដាក់ទំនិញនៅក្រោមរបបគយណាមួយ ប្រើសាមញ្ញកម្មប្រតិវេទន៍ទំនិញ ដោយអាចលុបចោលនូវព័ត៌មានខ្លះ និងឯកសារគាំទ្រមួយចំនួន ជាការតម្រូវរបស់ប្រតិវេទន៍ទំនិញ អាស្រ័យលើតម្រូវការ និងលក្ខខណ្ឌ ដែលបានដាក់។

២- ក្នុងករណីសាមញ្ញកម្មប្រតិវេទន៍ទំនិញ ប្រសិនបើតម្រូវដោយអាជ្ញាធរគយប្រទេសសមាជិកពាក់ព័ន្ធ ប្រតិវេទករត្រូវផ្តល់បន្ថែមនូវព័ត៌មាន និងឯកសារគាំទ្រដែលចាំបាច់សម្រាប់ប្រតិវេទន៍ទំនិញក្រោមរបបគយពាក់ព័ន្ធនៅពេលក្រោយ ។

## មាត្រា១៥.- ការរក្សាទុកប្រតិវេទន៍ទំនិញ និងឯកសារគាំទ្រ

ប្រតិវេទករ តម្រូវឲ្យរក្សាទុកប្រតិវេទន៍ទំនិញ និងឯកសារគាំទ្រ និងត្រូវបង្ហាញឯកសារទាំងនោះជូនទៅតាមសំណើរបស់អាជ្ញាធរគយ។ រយៈពេលនៃការរក្សាទុកឯកសារគាំទ្រត្រូវមានចែងក្នុងច្បាប់គយនៃបណ្តាប្រទេសសមាជិក។

## មាត្រា១៦.- ការបញ្ចេញទំនិញ

១- ក្នុងករណីដែលលក្ខខណ្ឌនៃការដាក់ទំនិញស្ថិតក្រោមនីតិវិធីគយពាក់ព័ន្ធណាមួយត្រូវបានបំពេញ និងផ្តល់ឲ្យ ដែលការដាក់កម្រិតកំណត់ត្រូវបានអនុវត្ត និងទំនិញពុំមែនជា

កម្មវត្ថុនៃមុខទំនិញហាមឃាត់ អាជ្ញាធរគយពាក់ព័ន្ធត្រូវអនុញ្ញាតឲ្យទំនិញចេញ ក្រោយពេលព័ត៌មាននៅក្នុងប្រតិវេទន៍ទំនិញ ត្រូវបានផ្ទៀងផ្ទាត់ និងទទួលយកចប់សព្វគ្រប់។

២- ក្នុងករណីការដាក់ទំនិញស្ថិតក្រោមនីតិវិធីគយពាក់ព័ន្ធណាមួយដែលធ្វើឲ្យមានកំណើនប្រាក់ពន្ធគយ និងអាករផ្សេងទៀត ការបញ្ចេញទំនិញត្រូវបំពេញលក្ខខណ្ឌបង់ប្រាក់ពន្ធនាំចូល ឬនាំចេញឲ្យស្របតាមប្រាក់ពន្ធគយនិងអាករផ្សេងទៀត ឬនិមុត្តិធានាដើម្បីធានាប្រាក់ពន្ធ និងអាករទាំងនោះ។

៣- អនុលោមតាមបញ្ញត្តិគ្រប់គ្រងនីតិវិធីគយចំពោះទំនិញត្រូវប្រកាស ហើយអាជ្ញាធរគយពាក់ព័ន្ធតម្រូវឲ្យដាក់និមុត្តិធានា ទំនិញទាំងនោះមិនត្រូវអនុញ្ញាតឲ្យចេញក្រោមនីតិវិធីគយណាទេ រហូតដល់និមុត្តិធានាត្រូវបានដាក់។

## មាត្រា១៧.- ការបំពេញបែបបទបញ្ចេញទំនិញពីគយ

១- អាជ្ញាធរគយប្រទេសសមាជិក អាចអនុញ្ញាតឲ្យបុគ្គលដាក់ប្រតិវេទន៍ទំនិញនៅការិយាល័យគយដែលបុគ្គលទទួលខុសត្រូវតាំងនៅ ខណៈដែលទំនិញស្ថិតនៅការិយាល័យគយមួយផ្សេងទៀត ។ ក្នុងករណីនេះ ពន្ធនិងអាករត្រូវបង់នៅការិយាល័យគយដែលប្រតិវេទន៍ទំនិញត្រូវបានដាក់។

២- ការិយាល័យគយដែលប្រតិវេទន៍ទំនិញបានដាក់ ត្រូវអនុវត្តទម្រង់ការផ្ទៀងផ្ទាត់ប្រតិវេទន៍ទំនិញ ទឹកប្រាក់សម្រាប់ពន្ធនាំចូល ឬនាំចេញ ឲ្យត្រូវគ្នាជាមួយពន្ធនិងអាករផ្សេងទៀត មុននឹងអនុញ្ញាតបញ្ចេញទំនិញ ។

## មាត្រា១៨.- ទំនិញសម្រាប់ចរាចរដោយសេរី

ការបញ្ចេញទំនិញសម្រាប់ចរាចរដោយសេរីក្នុងដែនគយរបស់ប្រទេសសមាជិក ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

ក- បានប្រមូលពន្ធនាំចូល និងអាករតាមកាលកំណត់។

ខ- ក្នុងករណីសមស្រប ការប្រមូលកម្រៃ និងសេវាផ្សេងទៀត ទៅតាមបញ្ញត្តិពាក់ព័ន្ធជាធរមាន ដូចមានចែងពីការប្រមូលកម្រៃ និងសេវាទាំងនេះ។

គ- កាអនុវត្តវិធានការគោលនយោបាយពាណិជ្ជកម្ម និងការហាមឃាត់ និងការដាក់កម្រិតកំណត់ មិនចាំបាច់អនុវត្តវិធានការទាំងនេះនៅដំណាក់កាលដំបូងឡើយ ។ និង

ឃ- ការបំពេញចប់សព្វគ្រប់នៃទម្រង់ការពាក់ព័ន្ធនានាអនុលោមតាមបែបបទនាំចូលទំនិញ។

**មាត្រា១៩.- តារាងនាមវលី**

តារាងនាមវលីដែលប្រើដោយបណ្តាប្រទេសសមាជិកសម្រាប់ចំណាត់ថ្នាក់ទំនិញ ត្រូវអនុលោមតាមតារាងនាមវលីស៊ីចង្វាក់អាស៊ាន និងវិសោធនកម្មរបស់វា ដោយឈរលើមូលដ្ឋានច្បាប់ចុងក្រោយនៃប្រព័ន្ធស៊ីចង្វាក់របស់អង្គការគយពិភពលោក។ អត្រាពន្ធគយ និងអាករ ត្រូវប្រកាសឲ្យដឹង ក្នុងការបោះពុម្ពផ្សាយជាផ្លូវការដោយបណ្តាប្រទេសសមាជិក។

**មាត្រា២០.- ការកំណត់តម្លៃគិតពន្ធគយ**

១- បណ្តាប្រទេសសមាជិក ត្រូវអនុវត្តកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃកិច្ចព្រមព្រៀងទូទៅស្តីពីអត្រាពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ (កិច្ចព្រមព្រៀងស្តីពីតម្លៃគិតពន្ធគយរបស់អង្គការគយពិភពលោក)តាមកាលបរិច្ឆេទ។

២- បណ្តាប្រទេសសមាជិក ត្រូវខិតខំអនុម័តអភិក្រមរួម ក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីតម្លៃគិតពន្ធគយរបស់អង្គការគយពិភពលោក។

**មាត្រា២១.- ការកំណត់ទំនិញមានតម្លៃទាប** (De Minimis)

បណ្តាប្រទេសសមាជិក ត្រូវពិចារណាកំណត់តម្លៃអប្បបរិមា និង/ឬ បរិមាណអប្បបរិមា និង/ឬ ចំនួនប្រាក់ពន្ធគយ និងអាករអប្បបរិមា ដែលស្ថិតនៅក្រោមប្រាក់ពន្ធគយ និងអាករត្រូវប្រមូល។

**មាត្រា២២.- ការកំណត់ដើមកំណើតទំនិញ**

បណ្តាប្រទេសសមាជិក ត្រូវចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវក្នុងការកំណត់ដើមកំណើតទំនិញសម្រាប់គោលបំណងគយ និងគោលបំណងផ្សេងទៀត។

## មាត្រា២៣.- ពន្ធគយ និងអាករ

១- បណ្តាប្រទេសសមាជិក ត្រូវកំណត់ក្នុងច្បាប់គយរបស់ខ្លួននូវពេលវេលានៃការប្រមូលពន្ធគយ និងអាករ និងពេលវេលាកំណត់សម្រាប់ការបង់ប្រាក់ពន្ធគយ និងអាករដែលបង់។

២- បណ្តាប្រទេសសមាជិក ត្រូវកំណត់ក្នុងច្បាប់គយរបស់ខ្លួននូវការបង់ប្រាក់ពន្ធគយ និងអាករជាទម្រង់សាច់ប្រាក់ ឬទម្រង់ទូទាត់ផ្សេងទៀត ដែលមានកម្រិតទូទាត់ប្រហាក់ប្រហែលគ្នា។

៣- បណ្តាប្រទេសសមាជិក ត្រូវខិតខំអនុញ្ញាតឲ្យមានការពន្យាពេលបង់ប្រាក់ពន្ធ និងអាករ ។ ក្នុងករណីការពន្យាពេលបង់ប្រាក់ពន្ធនិងអាករត្រូវអនុញ្ញាត លក្ខខណ្ឌ និងតម្រូវការចាំបាច់សម្រាប់ការពន្យាពេលបង់ប្រាក់ពន្ធ និងអាករ ត្រូវកំណត់ក្នុងច្បាប់គយរបស់ប្រទេសសមាជិកពាក់ព័ន្ធ។

## មាត្រា២៤.- និមុត្តិធានា

១- អាជ្ញាធរគយប្រទេសសមាជិក អាចតម្រូវឲ្យតម្កល់និមុត្តិធានាដើម្បីធានាការបង់ប្រាក់ពន្ធ និងអាករ ឬដើម្បីបំពេញកាតព្វកិច្ចផ្សេងទៀត។

២- ក្នុងករណីតម្រូវឲ្យតម្កល់និមុត្តិធានា ទឹកប្រាក់និមុត្តិធានាត្រូវមានកម្រិតទាបតាមដែលអាចធ្វើបាន។ ពាក់ព័ន្ធនឹងមានការបង់ពន្ធគយ និងអាករ ទឹកប្រាក់និមុត្តិធានា មិនត្រូវឲ្យលើសពីកាតព្វកិច្ចប្រាក់ពន្ធ និងអាករទេ។

៣- អាជ្ញាធរគយប្រទេសសមាជិក អាចសម្រេចមិនតម្រូវឲ្យតម្កល់និមុត្តិធានា ក្នុងករណីយល់ថា កាតព្វកិច្ចនានាចំពោះអាជ្ញាធរគយនឹងត្រូវបំពេញ។

៤- បណ្តាប្រទេសសមាជិក ត្រូវពិចារណាទទួលយកនិមុត្តិធានាជារួមមួយ ជំនួសនិមុត្តិធានាដោយឡែកទៅតាមករណីមួយៗ ជាពិសេសពីប្រតិវេទករដែលប្រកាសទំនិញជាប្រចាំនៅការិយាល័យគយផ្សេងគ្នារបស់ប្រទេសសមាជិកពាក់ព័ន្ធ។

៥- ក្នុងករណីនិមុត្តិធានាត្រូវបានដាក់តម្កល់ ទឹកប្រាក់និមុត្តិធានានេះត្រូវប្រគល់ឲ្យវិញឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពេលអាជ្ញាធរគយពាក់ព័ន្ធយល់ថា កាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់។

### មាត្រា២៥.- ការតម្កល់និមុត្តិធានា

ដោយមានការឯកភាពពីអាជ្ញាធរគយពាក់ព័ន្ធ និមុត្តិធានា អាចត្រូវតម្កល់ជាទម្រង់មួយ ដូចខាងក្រោម៖

ក- ដោយតម្កល់ជាសាច់ប្រាក់ ឬលិខិតុបករណ៍ហិរញ្ញវត្ថុផ្សេងទៀត
ខ- ដោយតម្កល់ជាប័ណ្ណដែលចេញដោយអ្នកធានា ឬ
គ- ដោយទម្រង់ផ្សេងទៀតនៃនិមុត្តិធានា ដែលមានការធានាប្រហាក់ប្រហែល

### មាត្រា២៦.- ការទូទាត់សងវិញ និងការសងប្រាក់ (ប្រាក់ពន្ធ អាករ និង កម្រៃផ្សេងៗ)

១- សេចក្តីសម្រេចលើការទាមទារឲ្យមានការទូទាត់សងវិញ ត្រូវយល់ព្រម និងជូនដំណឹងទៅឲ្យបុគ្គលពាក់ព័ន្ធជាលាយល័ក្ខណ៍អក្សរ ដោយគ្មានការពន្យាពេល និងចំនួនទឹកប្រាក់ដែលបង់លើស ត្រូវទូទាត់សងវិញឲ្យបានឆាប់តាមដែលអាចធ្វើបាន បន្ទាប់ពីការផ្ទៀងផ្ទាត់ការទាមទារនោះ។

២- ការសងប្រាក់ (ប្រាក់ពន្ធ អាករ និងកម្រៃផ្សេងៗ) ត្រូវធ្វើឡើងឲ្យបានឆាប់តាមដែលអាចធ្វើបាន បន្ទាប់ពីការផ្ទៀងផ្ទាត់ការទាមទារនោះ។

### មាត្រា២៧.- ការគ្រប់គ្រងហានិភ័យ

១- បណ្តាប្រទេសសមាជិក ត្រូវប្រើការគ្រប់គ្រងហានិភ័យក្នុងការត្រួតពិនិត្យគយដើម្បីពន្លឿនការបំពេញបែបបទបញ្ចេញទំនិញពីគយ។

២- ប្រទេសសមាជិកនីមួយៗ ត្រូវអនុម័តយុទ្ធសាស្ត្រវិធានការអនុលោមភាពមួយដើម្បីគាំទ្រការគ្រប់គ្រងហានិភ័យ។

### មាត្រា២៨.- សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ

១- បណ្តាប្រទេសសមាជិក ត្រូវអនុវត្តសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយក្នុងគោលបំណងលើកកម្ពស់អនុលោមភាព និងសម្រួលការបំពេញបែបបទបញ្ចេញទំនិញពីគយ។

២- ក្រោយពេលអនុញ្ញាតឲ្យទំនិញចេញ និងដើម្បីបញ្ជាក់ពីសុក្រឹតភាពនៃព័ត៌មានដែលមានក្នុងប្រតិវេទន៍ទំនិញ អាជ្ញាធរគយប្រទេសសមាជិកអាចធ្វើអធិការកិច្ចលើឯកសារ និងទិន្នន័យដែលពាក់ព័ន្ធនឹងប្រតិបត្តិការទំនិញសង្ស័យ ។ អាជ្ញាធរគយ អាចពិនិត្យឆែកឆេរទំនិញទាំងនោះ និង/ឬយកសំណាកគំរូ នៅពេលចាំបាច់។

### មាត្រា២៩.- សាមញ្ញកម្មនៃទម្រង់ការគយ និងការត្រួតពិនិត្យគយ

អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំធ្វើឲ្យសាមញ្ញទម្រង់ការគយ និងការត្រួតពិនិត្យគយ ។

### មាត្រា៣០.- ប្រព័ន្ធឆ្លងកាត់គយអាស៊ាន

បណ្តាប្រទេសសមាជិក ត្រូវអនុវត្តប្រព័ន្ធឆ្លងកាត់អាស៊ានដោយអនុលោមតាមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីកិច្ចសម្រួលទំនិញឆ្លងកាត់។

### មាត្រា៣១.- បញ្ជរតែមួយអាស៊ាន

បណ្តាប្រទេសសមាជិក ត្រូវអនុវត្តបញ្ជរតែមួយជាតិរបស់ខ្លួន និងបញ្ជរតែមួយអាស៊ានដោយអនុលោមតាមកិច្ចព្រមព្រៀងបង្កើត និងអនុវត្តបញ្ជរតែមួយអាស៊ាន និងពិធីការបង្កើតនិងអនុវត្តបញ្ជរតែមួយអាស៊ាន។

### មាត្រា៣២.- ប្រវេសន៍កាលិក

១- តាមលទ្ធភាពដែលអាចធ្វើទៅបាន បណ្តាប្រទេសសមាជិកត្រូវសម្រួលការធ្វើចរាចរទំនិញក្រោមរបបប្រវេសន៍កាលិក។

២- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវកំណត់រយៈពេលដែលទំនិញស្ថិតនៅក្រោមនីតិវិធីប្រវេសន៍កាលិក ហើយត្រូវនាំចេញទៅវិញ ឬត្រូវដាក់នៅក្រោមរបបគយបន្ទាប់ណាមួយ។

៣- ក្នុងកាលៈទេសៈលើកលែង ដែលទំនិញមិនអាចនាំចេញទៅវិញបាន ឬមិនអាចដាក់នៅក្រោមរបបគយបន្ទាប់ណាមួយបានក្នុងរយៈពេលកំណត់ អាជ្ញាធរគយពាក់ព័ន្ធអាចពន្យារពេលសម្រាប់រយៈពេលសមស្របមួយទៅតាមការស្នើសុំរបស់អ្នកកាន់កាប់ដែលទទួលការអនុញ្ញាត។

**មាត្រា៣៣.- គម្រូប្រព្រឹត្តកម្មទំនិញអាស៊ាន**

បណ្តាប្រទេសសមាជិក ត្រូវអនុវត្តគម្រូប្រព្រឹត្តកម្មទំនិញអាស៊ាន និងវិសោធនកម្មរបស់វា ជាឯកសារណែនាំដើម្បីសម្រួលពាណិជ្ជកម្ម និងវិនិយោគទុន ។

**មាត្រា៣៤.- វិធានកំណត់ជាមុន** (Advance Rulings)

អនុលោមតាមការអនុញ្ញាតដោយច្បាប់របស់ខ្លួន អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវផ្តល់ជាលាយលក្ខណ៍អក្សរនូវវិធានកំណត់ជាមុន ដោយអនុលោមតាមបញ្ញត្តិដែលមានចែង ក្នុងមាត្រា៦២ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ។

**មាត្រា៣៥.- ប្រតិបត្តិករសេដ្ឋកិច្ចទទួលការអនុញ្ញាត**

១- បណ្តាប្រទេសសមាជិក ត្រូវលើកកម្ពស់បង្កើតកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចទទួលការ អនុញ្ញាតជាតិដើម្បីពង្រឹងសន្តិសុខនៃចង្វាក់ផ្គត់ផ្គង់ និងសម្រួលពាណិជ្ជកម្មដោយឈរលើ មូលដ្ឋានក្របខណ្ឌបមាណីយសន្តិសុខនិងសម្រួលពាណិជ្ជកម្មពិភពលោក។

២- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំបង្កើតនូវយន្តការនៃកិច្ចសហប្រតិបត្តិការ ក្នុងគោលបំណងលើកកម្ពស់ការទទួលស្គាល់ទៅវិញទៅមកនូវលក្ខខណ្ឌនៃប្រតិបត្តិករសេដ្ឋកិច្ច ទទួលការអនុញ្ញាត និងការត្រួតពិនិត្យគយ។

**មាត្រា៣៦.- បញ្ញើទំនិញរហ័ស**

បណ្តាប្រទេសសមាជិក ត្រូវខិតខំបង្កើតយន្តការ និងវិធានការឲ្យបានគ្រប់គ្រាន់ដើម្បី សម្រួលការបំពេញបែបបទបញ្ចេញទំនិញពីគយនៃបញ្ញើទំនិញរហ័ស រួមមាន ការដាក់ និង ដំណើរការប្រតិវេទន៍ទំនិញ មុនពេលទំនិញមកដល់ ។

## ជំពូកទី៣
## ព័ត៌មានវិទ្យា និងបច្ចេកវិទ្យាទូរគមនាគមន៍

## មាត្រា៣៧.- ការអនុវត្តព័ត៌មានវិទ្យា និង បច្ចេកវិទ្យាទូរគមនាគមន៍ដោយគយ

១- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវប្រើបច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍ក្នុងប្រតិបត្តិការគយដើម្បីពង្រឹងការត្រួតពិនិត្យគយ និងសម្រួលពាណិជ្ជកម្ម។

២- បណ្តាប្រទេសសមាជិក ត្រូវពិចារណាផងដែរលើបទដ្ឋានពាក់ព័ន្ធ និងការអនុវត្តល្អដែលផ្តល់ជាអនុសាសន៍ដោយអង្គការអន្តរជាតិ នៅពេលដាក់អនុវត្តបច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍។

៣- ទម្រង់ការគយ ដែលអនុវត្តដោយបច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍ ត្រូវរួមបញ្ចូលទាំងហត្ថលេខាអេឡិចត្រូនិក ឬមធ្យោបាយកំណត់អត្តសញ្ញាណផ្សេងទៀត ។

## មាត្រា៣៨.- ប៉ារ៉ាម៉ែត្រព័ត៌មាន និងទិន្នន័យ

ដោយយល់ថាសមស្រប អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវរៀបចំប៉ារ៉ាម៉ែត្រព័ត៌មាន និងទិន្នន័យនៃការធ្វើបែបបទបញ្ចេញទំនិញពីគយឲ្យស៊ីចង្វាក់នឹងបទដ្ឋានអន្តរជាតិ ដែលបានឯកភាពដោយបណ្តាប្រទេសសមាជិក។

## មាត្រា៣៩.- លទ្ធភាពដំណើរការប្រព័ន្ធរួម និងលទ្ធភាពតភ្ជាប់

បណ្តាប្រទេសសមាជិក ត្រូវខិតខំដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មគយរបស់ខ្លួនសម្រាប់ដំណើរការរួម និងតភ្ជាប់គ្នាទៅវិញទៅមក ក្នុងគោលបំណងលើកកម្ពស់ការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមអាជ្ញាធរគយ។

## មាត្រា៤០.- ការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន

អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវបានលើកទឹកចិត្តឲ្យចែករំលែក និងផ្លាស់ប្តូរព័ត៌មានតាមរយៈប្រព័ន្ធតភ្ជាប់គ្នាក្នុងគោលបំណងគយ ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងកិច្ចព្រមព្រៀងផ្សេងទៀតដែលចាំបាច់តាមច្បាប់អនុញ្ញាត និងស្ថិតនៅក្នុងលទ្ធភាព និងធនធានដែលមានកំណត់របស់ប្រទេសសមាជិក។

**មាត្រា៤១.- សន្តិសុខព័ត៌មាន និងទិន្នន័យ**

អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវមានវិធានការគ្រប់គ្រាន់ពាក់ព័ន្ធនឹងភាពអាចចូលទៅដល់ ភាពត្រឹមត្រូវ ភាពសុចរិត និងភាពឯកជននៃព័ត៌មានក្នុងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ រួមបញ្ចូលនូវដំណើរការផ្លាស់ប្តូរទិន្នន័យរវាងអាជ្ញាធរគយ។

## ជំពូកទី៤
## ការអនុវត្តច្បាប់គយ និងការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយ

**មាត្រា៤២.- ការការពារសហគមន៍អាស៊ាន**

អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំសហការគ្នាទៅវិញទៅមក និងជាមួយភ្នាក់ងារពាក់ព័ន្ធ ដើម្បីការពារសហគមន៍អាស៊ាន តាមរយៈការអនុវត្តសកម្មភាពច្បាស់លាស់សម្រាប់ប្រយុទ្ធប្រឆាំងបទល្មើសគយ បទឧក្រិដ្ឋ និងឧក្រិដ្ឋកម្មឆ្លងដែនដែលស្ថិតក្នុងសមត្ថកិច្ចនិងកម្មវត្ថុនៃច្បាប់របស់ប្រទេសសមាជិក រួមបញ្ចូលការជួញដូរគ្រឿងញៀនខុសច្បាប់ ការរំលោភកម្មសិទ្ធិបញ្ញា ការសម្អាតប្រាក់ អំពើភេរវកម្ម និងការជួញដូរមនុស្ស។

**មាត្រា៤៣.- វិស័យនៃកិច្ចសហប្រតិបត្តិការ**

អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំផ្តល់នូវការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយក្នុងការទប់ស្កាត់ ការស៊ើបអង្កេត និងការបង្ក្រាបបទល្មើសក្នុងវិស័យដូចខាងក្រោម៖

ក- បទល្មើសគយ

ខ- ការជួញដូរគ្រឿងញៀនខុសច្បាប់ សារធាតុដែលប៉ះពាល់ស្មារតី និងជាតុផ្សំ

គ- ការរំលោភកម្មសិទ្ធិបញ្ញា និង

ឃ- ការធ្វើពាណិជ្ជកម្មខុសច្បាប់លើស្នាដៃសិល្បៈ វត្ថុបុរាណ និងវត្ថុសិប្បនិម្មិតវប្បធម៌ផ្សេងទៀត។

## មាត្រា៤៤.- យន្តការនៃកិច្ចសហប្រតិបត្តិការ

១- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំសហការជាមួយគ្នាទៅវិញទៅមកក្នុងការផ្លាស់ប្តូរព័ត៌មាន និងព័ត៌មានសម្ងាត់ ឬសកម្មភាពផ្សេងទៀតតាមការឯកភាពគ្នា។

២- អាជ្ញាធរគយប្រទេសសមាជិក ត្រូវបង្កើតមន្ត្រីបង្គោល ក្នុងគោលបំណងផ្តល់ការជួយគ្នាទៅវិញទៅមកលើការងារគយដែលស្ថិតក្រោមជំពូកនេះ។

៣- តាមសំណើសុំរបស់អាជ្ញាធរគយប្រទេសសមាជិក អាជ្ញាធរគយទទួលសំណើសុំរបស់ប្រទេសសមាជិកមួយទៀត ត្រូវខិតខំផ្តល់ព័ត៌មានពាក់ព័ន្ធដូចខាងក្រោម៖

ក- ភាពត្រឹមត្រូវ និងភាពសុក្រឹតនៃឯកសារដែលប្រើសម្រាប់គាំទ្រប្រតិវេទន៍ទំនិញដែលបានដាក់ទៅឲ្យអាជ្ញាធរគយស្នើសុំ។

ខ- ទំនិញដែលបាននាំចូលដែនដីនៃប្រទេសសមាជិក ត្រូវបាននាំចេញស្របច្បាប់ពីដែនដីរបស់ប្រទេសសមាជិកមួយទៀត។

គ- ទំនិញដែលបាននាំចេញពីដែនដីនៃប្រទេសសមាជិក ត្រូវបាននាំចូលស្របច្បាប់ទៅក្នុងដែនដីរបស់ប្រទេសសមាជិកមួយទៀត និងបានដាក់ក្រោមនីតិវិធីគយ ប្រសិនបើមាន។

ឃ- បុគ្គលសង្ស័យ និង/ឬធ្លាប់ប្រព្រឹត្តបទល្មើសគយ

ង- វិធីសាស្ត្រ និងលិខិតុបករណ៍អនុវត្តច្បាប់ដែលបង្ហាញថាមានប្រសិទ្ធភាព

ច- និន្នាការ មធ្យោបាយ វិធីសាស្ត្រ ឬបែបបទប្រតិបត្តិការនៃការរត់ពន្ធ និងប្រព្រឹត្តបទល្មើស និងការបន្លំគយ

ឆ- បញ្ហាផ្សេងទៀត តាមការឯកភាពគ្នា

## មាត្រា៤៥.- ករូមិតទំហំវិសាលភាពនៃសកម្មភាពក្រោមការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយ

១- ទំហំវិសាលភាពនៃការជួយគ្នាដែលផ្តល់ដោយអាជ្ញាធរគយប្រទេសសមាជិកក្នុងជំពូកនេះ ត្រូវអនុលោមតាមច្បាប់ប្រទេសសមាជិក និងស្ថិតនៅក្នុងលទ្ធភាព និងធនធានដែលមានកំណត់របស់អាជ្ញាធរគយ។

២- ប្រសិនបើការស្នើសុំជួយ ធ្វើឲ្យប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខ ឬផលប្រយោជន៍ជាតិ ឬការខូតខាតប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់នៃសហគ្រាសឯកជន ឬរដ្ឋ

អាជ្ញាធរគយប្រទេសសមាជិកអាចបដិសេធមិនផ្តល់ការជួយ ឬផ្តល់ហេតុផលអនុលោមតាមលក្ខខណ្ឌ ឬតម្រូវការចាំបាច់មួយចំនួន។

៣- ជំពូកនេះ គ្រប់ដណ្តប់តែការជួយគ្នាទៅវិញទៅមកលើការងាររដ្ឋបាលគយរវាងអាជ្ញាធរគយបណ្តាប្រទេសសមាជិក និងមិនមានបំណងធ្វើឲ្យប៉ះពាល់ដល់កិច្ចព្រមព្រៀងស្របច្បាប់លើការជួយគ្នាទៅវិញទៅមក ឬកិច្ចព្រមព្រៀងផ្សេងទៀតនៃបណ្តាប្រទេសសមាជិក។

## ជំពូកទី៥

## កិច្ចសហប្រតិបត្តិការនៃការគ្រប់គ្រងសម្របសម្រួលព្រំដែន

### មាត្រា៤៦.- ភាពជាដៃគូជាមួយភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀតសម្រាប់ការគ្រប់គ្រងសម្របសម្រួលព្រំដែន

១- តាមដែលអាចធ្វើទៅបាន ប្រទេសសមាជិក ត្រូវពង្រឹងភាពជាដៃគូនៃអាជ្ញាធរគយរបស់ខ្លួនជាមួយភ្នាក់ងារពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រងសម្របសម្រួលព្រំដែន និងអនុលោមតាមច្បាប់ជាតិរបស់ប្រទេសសមាជិកពាក់ព័ន្ធ។

### មាត្រា៤៧.- ការសម្របសម្រួលត្រួតពិនិត្យព្រំដែន និងរួមគ្នា

១- ក្នុងករណីការត្រួតពិនិត្យក្រៅពីការត្រួតពិនិត្យគយ ដែលត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចក្រៅពីអាជ្ញាធរគយ ក្នុងកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចទាំងនោះ អាជ្ញាធរគយត្រូវខិតខំជួយអនុវត្តការត្រួតពិនិត្យនេះនៅទីកន្លែង និងពេលតែមួយ តាមដែលអាចធ្វើទៅបាន ដូចជាការត្រួតពិនិត្យគយ ដែលអាជ្ញាធរគយមានតួនាទីសម្របសម្រួលដើម្បីសម្រេចឲ្យបាននូវការត្រួតពិនិត្យនេះ។

២- ប្រទេសសមាជិក ត្រូវខិតខំបង្កើតការធ្វើអធិការកិច្ចជារូបវន្តរួម ឬការសម្របសម្រួលគ្នារវាងអាជ្ញាធរគយរបស់ខ្លួននិងភ្នាក់ងារពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលបំណងពន្លឿនការធ្វើបែបបទបញ្ចេញទំនិញពីគយ និងការបញ្ចេញទំនិញដើម្បីសម្រួលពាណិជ្ជកម្ម។

## ជំពូកទី៦
## ភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធគយ

### មាត្រា៤៨.- ភាពអាចរកបាននៃព័ត៌មាន

១- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវផ្តល់ឲ្យបុគ្គលធ្វើសំណើសុំដែលមានលក្ខណៈសម្បត្តិ នូវព័ត៌មានពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ លើកឡើងដោយបុគ្គលនោះស្របតាមច្បាប់គយ និងបែបបទរដ្ឋបាលរបស់ខ្លួន លើកលែងតែព័ត៌មានសម្ងាត់។

២- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវតែងតាំងចំណុចទំនាក់ទំនងមួយ ឬច្រើនដើម្បីឆ្លើយតបនឹងសំណួរពាក់ព័ន្ធនឹងការងារគយពីបុគ្គលដែលធ្វើសំណើសុំដែលមានលក្ខណៈសម្បត្តិ និងត្រូវដាក់ព័ត៌មានសំណួរពាក់ព័ន្ធនីតិវិធីលើគេហទំព័រ និង/ឬជាទម្រង់បោះពុម្ព។

៣- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវបោះពុម្ពផ្សាយលើគេហទំព័រ និង/ឬជាទម្រង់បោះពុម្ពនូវរាល់ច្បាប់គយ និងបែបបទរដ្ឋបាល លើកលែងតែព័ត៌មានសម្ងាត់។

### មាត្រា៤៩.- ការពិគ្រោះយោបល់ជាមួយផ្នែកឯកជន

១- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវពង្រឹងភាពជាដៃគូជាមួយផ្នែកឯកជនក្នុងគោលបំណងពន្លឿនការធ្វើបែបបទបញ្ចេញទំនិញពីគយ និងការបញ្ចេញទំនិញ និងពង្រឹងនីតិវិធីគយ។

២- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំរៀបចំកិច្ចពិភាក្សាឲ្យបានទៀងទាត់ជាមួយផ្នែកឯកជននៅកម្រិតថ្នាក់ជាតិ និងតំបន់។

### មាត្រា៥០.- បមាណីយកម្មសេវា

អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំផ្តល់សេវាឲ្យបានល្អដល់សាធារណជន និងសហគមន៍ពាណិជ្ជកម្ម តាមរយៈការបង្កើតបមាណីយកម្មសេវា និងសូចនាករបម្រើសេវា។

### មាត្រា៥១.- កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងសហគមន៍គយអន្តរជាតិ

១- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងសហគមន៍គយអន្តរជាតិ ដើម្បីធ្វើទំនើបកម្មការអនុវត្តនីតិវិធីគយ និងបង្ក្រាបគម្លាតកិច្ចអភិវឌ្ឍន៍ ។

២- អាជ្ញាធរគយបណ្តាប្រទេសសមាជិក ត្រូវខិតខំផ្លាស់ប្តូរទស្សនជាមួយអាជ្ញាធរគយផ្សេងទៀត ក្នុងគោលបំណងពង្រឹងការយោគយល់គ្នាទៅវិញទៅមក និងលើកកម្ពស់ផលប្រយោជន៍អាស៊ាន។

## ជំពូកទី៧
## បណ្តឹងឧទ្ធរណ៍

### មាត្រា៥២.- សិទ្ធិនៃការពិនិត្យឡើងវិញ និងបណ្តឹងឧទ្ធរណ៍

១- ប្រទេសសមាជិកត្រូវធានាថា ក្នុងដែនដីរបស់ខ្លួន បុគ្គលណាដែលទទួលផលប៉ះពាល់ដោយសារសេចក្តីសម្រេចរបស់អាជ្ញាធរគយ មានលទ្ធភាពទទួលបានការពិនិត្យឡើងវិញផ្នែករដ្ឋបាលពីអាជ្ញាធរគយដែលចេញសេចក្តីសម្រេចនោះ ក្នុងករណីអនុញ្ញាតឲ្យពិនិត្យឡើងវិញដោយអាជ្ញាធរជាន់ខ្ពស់ដែលទទួលបន្ទុកអាជ្ញាធរគយ និង/ឬការពិនិត្យឡើងវិញដោយតុលាការដែលជាដំណាក់កាលកំណត់ចុងក្រោយនៃការពិនិត្យឡើងវិញនូវសេចក្តីសម្រេច ដោយអនុលោមតាមច្បាប់របស់ប្រទេសសមាជិក។

២- សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍ ត្រូវផ្តល់ឲ្យទៅអ្នកប្តឹងឧទ្ធរណ៍ និងហេតុផលនៃសេចក្តីសម្រេចនេះ ត្រូវផ្តល់ជាលាយលក្ខណ៍អក្សរ។

## ជំពូកទី៨
## ការអនុវត្ត និងស្ថាប័នចាត់ចែង

### មាត្រា៥៣.- ស្ថាប័នចាត់ចែង

១- កិច្ចប្រជុំអគ្គនាយកគយអាស៊ានក្រោមការត្រួតពិនិត្យរបស់កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ត្រូវត្រួតពិនិត្យ ពិនិត្យឡើងវិញ និងសម្របសម្រួលរាល់ទិដ្ឋភាពពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។ កិច្ចប្រជុំអគ្គនាយកគយអាស៊ាន អាចបង្កើតក្រុមការងារពាក់ព័ន្ធដើម្បីជួយគាំទ្រក្នុងការបំពេញភារកិច្ច ក្រោមកិច្ចព្រមព្រៀងនេះ។

២- កិច្ចប្រជុំអគ្គនាយកគយអាស៊ាន ត្រូវធ្វើការវាយតម្លៃជាប្រចាំពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ ដោយផ្អែកលើមូលដ្ឋានផែនការការងារដែលស្ថិតនៅក្រោមក្រុមការងារពាក់ព័ន្ធ ក្នុងគោលបំណងកំណត់វិធានការសមស្រប ដើម្បីធានាការធ្វើសេចក្តីសម្រេចចិត្តឲ្យទាន់ពេលវេលា ។ របាយការណ៍នៃលទ្ធផលការងារ នឹងត្រូវដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន។

៣- លេខាធិការដ្ឋានអាស៊ាន ត្រូវ៖

ក- ផ្តល់កិច្ចគាំទ្រដល់កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន កិច្ចប្រជុំអគ្គនាយកគយអាស៊ាន និងក្រុមការងារពាក់ព័ន្ធ ដោយយោងទៅនឹងកថាខណ្ឌទី១ ក្នុងការត្រួតពិនិត្យ ការសម្របសម្រួល និងការពិនិត្យឡើងវិញនៃការអនុវត្តកិច្ចព្រមព្រៀងនេះ ព្រមទាំងការជួយពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ និង

ខ- តាមដាន និងរាយការណ៍ជាប្រចាំទៅកិច្ចប្រជុំអគ្គនាយកគយអាស៊ានស្តីពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ។

## មាត្រា៥៤.- ការធ្វើសេចក្តីសម្រេច

១- សេចក្តីសម្រេចដោយកិច្ចប្រជុំអគ្គនាយកគយអាស៊ាន ពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងបន្ទាប់ពីមានកិច្ចពិភាក្សា និងព្រមព្រៀងគ្នាដោយឯកច្ឆន្ទ។

២- សេចក្តីសម្រេចដែលធ្វើឡើងដោយកិច្ចប្រជុំអគ្គនាយកគយអាស៊ាន ត្រូវអនុវត្តឲ្យឯកភាពគ្នា និងទាន់ពេលវេលា។

## មាត្រា៥៥.- ការពិគ្រោះយោបល់

បណ្តាប្រទេសសមាជិក ត្រូវខិតខំពិគ្រោះយោបល់គ្នានៅកម្រិតកិច្ចប្រជុំអគ្គនាយកគយអាស៊ាន និងបើអាចធ្វើទៅបាន នៅកម្រិតក្រុមការងារពាក់ព័ន្ធនឹងបញ្ហាគយ ឬវិធានការគយនានាដែលអាចប៉ះពាល់ដល់ទំនិញដែលធ្វើពាណិជ្ជកម្មក្នុងចំណោមបណ្តាប្រទេសសមាជិក ឬរាំងដល់ការសម្រេចគោលបំណងនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៥៦.- យន្តការពិគ្រោះយោបល់ និងប្រឹក្សាយោបល់

កិច្ចពិគ្រោះយោបល់អាស៊ានដើម្បីដោះស្រាយបញ្ហាពាណិជ្ជកម្ម និងវិនិយោគទុន (ACT) និងក្រុមតាមដានអនុលោមភាពអាស៊ាន (ACMB) ដែលចែងក្នុងសេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀង

អាស៊ានII (កិច្ចព្រមព្រៀងប៉ាលី II) អាចត្រូវយកមកប្រើដើម្បីដោះស្រាយជម្លោះដែលអាចកើតឡើងពីកិច្ចព្រមព្រៀងនេះ។ ប្រទេសសមាជិកណាមួយ ដែលមិនមានបំណងប្រើ ACT/ACMB អាចប្រើយន្តការដែលចែងក្នុងពិធីសារអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ។

**មាត្រា៥៧.- ការដោះស្រាយជម្លោះ**

ពិធីសារអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀចាន់ ប្រទេសឡាវ និងវិសោធនកម្មរបស់វា ត្រូវអនុវត្តចំពោះជម្លោះដែលកើតឡើងពី ឬភាពខុសគ្នានៃការបកស្រាយការអនុវត្តកិច្ចព្រមព្រៀងនេះរវាងប្រទេសសមាជិកពាក់ព័ន្ធ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៥៨.- ការសម្ងាត់**

១- គ្មានបញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយក្នុងន័យតម្រូវឲ្យប្រទេសសមាជិកណាមួយ ផ្តល់ ឬអនុញ្ញាតឲ្យទទួលបានព័ត៌មានសម្ងាត់ អនុលោមតាមកិច្ចព្រមព្រៀងនេះ ការលាតត្រដាងព័ត៌មានសម្ងាត់ទាំងនេះ អាចនឹង៖

ក- ផ្ទុយពីផលប្រយោជន៍សាធារណៈដែលកំណត់ដោយច្បាប់របស់ខ្លួន

ខ- ផ្ទុយពីច្បាប់មួយក្នុងចំណោមច្បាប់របស់ខ្លួន ដោយមិនកំណត់រួមទាំង ច្បាប់ការពារសិទ្ធិឯកជនបុគ្គល ឬបញ្ហាហិរញ្ញវត្ថុ និងគណនេយ្យអតិថិជននៃស្ថាប័នហិរញ្ញវត្ថុ

គ- រារាំងដល់ការអនុវត្តច្បាប់

ឃ- ធ្វើឲ្យខូចខាតផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ ដែលអាចរួមទាំងការប្រកួតប្រជែងរបស់សហគ្រាសរដ្ឋ និងឯកជន។

២- ក្នុងករណីដែលប្រទេសសមាជិកមួយផ្តល់ព័ត៌មានឲ្យប្រទេសសមាជិកមួយទៀតអនុលោមតាមកិច្ចព្រមព្រៀងនេះ និងចាត់ទុកព័ត៌មាននេះជាការសម្ងាត់ ប្រទេសសមាជិកទទួលព័ត៌មានត្រូវរក្សាការសម្ងាត់នៃព័ត៌មាន ប្រើព័ត៌មាននេះសម្រាប់តែគោលបំណងដែលបានបញ្ជាក់

ដោយប្រទេសសមាជិកផ្តល់ពត៌មាន និងមិនត្រូវផ្សព្វផ្សាយព័ត៌មាននេះដោយគ្មានការអនុញ្ញាត ជាលាយលក្ខណ៍អក្សរជាក់លាក់ពីប្រទេសសមាជិកដែលផ្តល់ព័ត៌មាននេះ។

៣- កាតព្វកិច្ចនេះ ត្រូវសង្កេតមើលដោយបណ្តាប្រទេសសមាជិក ក្នុងអំឡុងពេលសុពលភាពនៃកិច្ចព្រមព្រៀងនេះ និងក្រោយពេលការអស់សុពលភាព ឬការបញ្ចប់កិច្ចព្រមព្រៀងនេះ លើកលែងតែមានការព្រមព្រៀងដោយឡែកដោយបណ្តាសមាជិកពាក់ព័ន្ធ។

## មាត្រា៥៩.- ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងអាស៊ានផ្សេងទៀត

ក្នុងករណីមិនមានសង្គតិភាពរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានផ្សេងទៀតពាក់ព័ន្ធនឹងបញ្ហាគយ កិច្ចព្រមព្រៀងនេះ ត្រូវបានយកជាគោល។

## មាត្រា៦០.- ការកែប្រែ ឬជំនួសដោយកិច្ចព្រមព្រៀងអន្តរជាតិ

ប្រសិនបើកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ឬបញ្ញត្តិដែលចែងនៅក្នុងនោះ ឬបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀង ឬបទប្បញ្ញត្តិទាំងនោះត្រូវបានកែប្រែ បណ្តាប្រទេសសមាជិកត្រូវពិគ្រោះថាតើវាចាំបាច់កែប្រែកិច្ចព្រមព្រៀងនេះដែរឬទេ លើកលែងតែកិច្ចព្រមព្រៀងចែងផ្សេងពីនេះ។

## មាត្រា៦១.- ឧបសម្ព័ន្ធ ឯកសារភ្ជាប់ និងលិខិតតុបករណ៍នាពេលអនាគត

បណ្តាប្រទេសសមាជិក អាចអនុម័តរួមគ្នានូវឧបសម្ព័ន្ធ និងលិខិតតុបករណ៍នាពេលអនាគត ដែលពាក់ព័ន្ធនឹងបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។ ឧបសម្ព័ន្ធ និងលិខិតតុបករណ៍ទាំងនេះត្រូវជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ក្រោយពេលបានដាក់ចូលជាធរមាន។

## មាត្រា៦២.- វិសោធនកម្ម

កិច្ចព្រមព្រៀងនេះ និងឧបសម្ព័ន្ធ និងលិខិតតុបករណ៍របស់វា ប្រសិនបើមាន អាចធ្វើវិសោធនកម្ម ដោយមានការព្រៀមព្រៀងជាលាយលក្ខណ៍អក្សរពីបណ្តាប្រទេសសមាជិក។

## មាត្រា៦៣.- ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន ក្រោយពេលបណ្តាប្រទេសសមាជិកបានជូនដំណឹង ឬបើចាំបាច់ បានដាក់តម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ននៅលេខាធិការដ្ឋានអាស៊ានបន្ទាប់ពីការបញ្ចប់បែបបទផ្ទៃក្នុងរបស់ខ្លួនដែលមានរយៈពេលមិនលើសពី ១៨០ ថ្ងៃ ក្រោយពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

២- លេខាធិការដ្ឋានអាស៊ាន ត្រូវជូនដំណឹងដល់បណ្តាប្រទេសសមាជិកពីការតម្កល់ ឬសេចក្តីជូនដំណឹងនៃលិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ដែលអនុលោមតាមកថាខណ្ឌទី១ នៃមាត្រានេះ។

៣- បន្ទាប់ពីចូលជាធរមាន កិច្ចព្រមព្រៀងនេះ ត្រូវបានជំនួសកិច្ចព្រមព្រៀងស្តីពីគយ ដែលបានចុះហត្ថលេខានាថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៧ នៅទីក្រុងភូកេត ប្រទេសថៃ។

៤- ឧបសម្ព័ន្ធ និងពិធីសារដែលបានបញ្ចូលជាផ្នែកនៃកិច្ចព្រមព្រៀងស្តីពីគយ ដែលបានចុះហត្ថលេខានាថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៧ នៅទីក្រុងភូកេត ប្រទេសថៃ និងបានចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ រួមមានពិធីការគ្រប់គ្រងការអនុវត្តនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់អាស៊ានដែលបានធ្វើឡើងនាថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន និងបណ្តាឧបសម្ព័ន្ធ និងពិធីសារផ្សេងទៀត បន្ថែមលើពិធីសារដែលបានរៀបរាប់ខាងលើ ត្រូវបញ្ចូលជាផ្នែកនៃកិច្ចព្រមព្រៀងនេះ និងមានតម្លៃអនុវត្តដូចគ្នា។ ឯកសារយោងនៃកិច្ចព្រមព្រៀងនេះ ត្រូវចាត់ទុកផងដែរជាឯកសារយោងនៃឧបសម្ព័ន្ធ និងពិធីសារទាំងនេះ។

## មាត្រា៦៤.- ការបម្រុងទុក

គ្មានការបម្រុងទុកណាមួយត្រូវបានធ្វើឡើង ដោយគោរពទៅតាមបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា៦៥.- ការតម្កល់ឯកសារ

កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវមួយច្បាប់ដល់សមាជិកនីមួយៗ ។

| ៣ | អនុសេនីយ៍ទោ | និត្យ | រ៉ាឆាន | អត្តលេខ ០២២១៥៧ មេបញ្ជាការអនុសេនាតូចអនុសេនាធំការពារ អាកាស កងពលតូចថ្មើរជើងលេខ៥២ |
| ៤ | អនុសេនីយ៍ត្រី | ភាន | សម្បត្តិ | អត្តលេខ ០៣៣៦៣២ មេបញ្ជាការរងអនុសេនាតូចទី៣ អនុសេនាធំទី២ វរសេនាតូច៥២៣ កងពលតូចថ្មើរជើង លេខ៥២ |
| ៥ | អនុសេនីយ៍ត្រី | ខាត់ | ធន | អត្តលេខ ០៣៥១៣៨ មេក្រុមអនុសេនាធំទី៣ វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ៦ | អនុសេនីយ៍ត្រី | ហ៊ឹម | សុខន | អត្តលេខ ០៣៣៧៨៨ មេបញ្ជាការអនុសេនាតូច អនុសេនាធំបញ្ជូនសារ កងពលតូចថ្មើរជើងលេខ៥២ |
| ៧ | អនុសេនីយ៍ត្រី | ផាន់ | ភឿន | អត្តលេខ ១៦០១៩៨ ជំនួយការហ្វឹកហ្វឺន កងពលតូចថ្មើរជើងលេខ៥២ |
| ៨ | អនុសេនីយ៍ត្រី | ផាត់ | ទិរុទ្ធ | អត្តលេខ ០៣៣៧៥៧ មេបញ្ជាការអនុសេនាតូច អនុសេនាធំវិស្វកម្ម កងពលតូចថ្មើរជើងលេខ៥២ |
| ៩ | អនុសេនីយ៍ត្រី | អេង | អៀម | អត្តលេខ ០៣៧៥២៩ មេបញ្ជាការអនុសេនាតូច អនុសេនាធំវិស្វកម្ម វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ១០ | អនុសេនីយ៍ត្រី | ឡុយ | វ៉េត | អត្តលេខ ០៤៤៧៩៨ មេបញ្ជាការអនុសេនាតូច អនុសេនាធំគាំទ្រ កងពលតូចថ្មើរជើងលេខ៥២ |

| | | | | |
|---|---|---|---|---|
| ១១ | អនុសេនីយ៍ត្រី | រ៉ុំ | សុខុម | អត្តលេខ ០៤៤៧៧១ ជំនួយការ ការិយាល័យសុខាភិបាល កងពលតូចថ្មើរជើងលេខ៥២ |
| ១២ | អនុសេនីយ៍ត្រី | ផាន់ | ហ៊ត | អត្តលេខ ០៣៣៧៤៧ មេបញ្ជាការរងអនុសេនាតូច អនុសេនាធំដឹកជញ្ជូន កងពលតូចថ្មើរជើងលេខ៥២ |
| ១៣ | នាយចំណង់ | ទ៊ាន់ | ស៊ិន | អត្តលេខ ០៤៦២៦០ មេក្រុមអនុសេនាតូចស៊ើបការណ៍ វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ១៤ | នាយចំណង់ | សន | ពិសិដ្ឋ | អត្តលេខ ០៤៧៧៦៥ បុគ្គលិកវិស្វកម្ម អនុសេនាធំបញ្ជូនសារ កងពលតូចថ្មើរជើងលេខ៥២ |
| ១៥ | នាយចំណង់ | នៅ | សាទី | អត្តលេខ ០៤៧៧៦០ បុគ្គលិកវិស្វកម្ម អនុសេនាធំបញ្ជូនសារ កងពលតូចថ្មើរជើងលេខ៥២ |
| ១៦ | នាយចំណង់ | ផាត់ | ភារម្យ | អត្តលេខ ០៤៤៨១១ មេបញ្ជាការអនុសេនាតូច អនុសេនាធំវិស្វកម្ម កងពលតូចថ្មើរជើងលេខ៥២ |
| ១៧ | នាយចំណង់ | ផាត់ | ទិរៈ | អត្តលេខ ០៤៦០០៩ មេបញ្ជាការ អនុសេនាតូច អនុសេនាធំវិស្វកម្ម កងពលតូចថ្មើរជើងលេខ៥២ |
| ១៨ | នាយចំណង់ | ចាន់ | ណារ៉ុស្រ៊ិន | អត្តលេខ ០៤៤៨៥១ មេក្រុមអនុសេនាធំដឹកជញ្ជូន កងពលតូចថ្មើរជើងលេខ៥២ |
| ១៩ | នាយចំណង់ | ពាន | សុខសាន្ត | អត្តលេខ ០៨៣០២២ ជំនួយការ អាវុធគ្រាប់ការិយាល័យបច្ចេកទេស កងពលតូចថ្មើរជើងលេខ៥១ |
| ២០ | ព្រិន្ទបាលឯក | ខៀវ | សុខ | អត្តលេខ ០១៦២៣០ មេក្រុមអនុសេនាតូចស៊ើបការណ៍ វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ២១ | ព្រិន្ទបាលឯក | នី | សារឿន | អត្តលេខ ១៦០៣៣៧ បុគ្គលិកភស្តុភារអនុសេនាធំទី៣ វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ២២ | ព្រិន្ទបាលឯក | គឿន | សុភា | អត្តលេខ ១៦៦៥៩០ មេបញ្ជាការរងអនុសេនាតូចទី១ អនុសេនាធំទី៣ វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ២៣ | ព្រិន្ទបាលឯក | រ៉ូ | អឿន | អត្តលេខ ២២៩០៧០ ជំនួយការ ការិយាល័យសុខាភិបាល កងពលតូចថ្មើរជើងលេខ៥២ |
| ២៤ | ព្រិន្ទបាលឯក | សួន | ស៊ីទ៊ាន់ថា | អត្តលេខ ១៦៦៩៧៤ ជំនួយការប្រតិបត្តិការ វរសេនាតូច៥២១ កងពលតូចថ្មើរជើងលេខ៥២ |
| ២៥ | ព្រិន្ទបាលឯក | លួត | សារី | អត្តលេខ ១៦០២៩៦ មេក្រុម វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ២៦ | ព្រិន្ទបាលឯក | ម៉ិល | ដានី | អត្តលេខ ១៦៦៦៩៣ មេក្រុម វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ២៧ | ព្រិន្ទបាលឯក | ហុង | រ៉ា | អត្តលេខ ១៦០៧៤៩ មេក្រុម វរសេនាតូច៥២៣ កងពលតូចថ្មើរជើងលេខ៥២ |
| ២៨ | ព្រិន្ទបាលឯក | សឿន | សល់ | អត្តលេខ ១៦០៧៣១ មេក្រុម វរសេនាតូច៥២១ កងពលតូចថ្មើរជើងលេខ៥២ |
| ២៩ | ព្រិន្ទបាលឯក | ញឹក | អេម | អត្តលេខ ១៦០១៩៣ មេក្រុម វរសេនាតូច៥២១ កងពលតូចថ្មើរជើងលេខ៥២ |
| ៣០ | ព្រិន្ទបាលឯក | ម៉ែន | សំណោត | អត្តលេខ ១៦០២៦៧ ជំនួយការការិយាល័យទី១ កងពលតូចថ្មើរជើងលេខ៥២ |
| ៣១ | ព្រិន្ទបាលឯក | ស៊ឹង | ម៉ុនធី | អត្តលេខ ០៦១៣៤៤ មេបញ្ជាការ អនុសេនាតូចដឹកជញ្ជូន វរសេនាតូច៥១៣ កងពលតូចថ្មើរជើងលេខ៥១ |
| ៣២ | ព្រិន្ទបាលឯក | អ៊ូ | ឈឿ | អត្តលេខ ០៥៣០៦០ បុគ្គលិក គិលានដ្ឋាន កងពលតូចថ្មើរជើងលេខ៥១ |
| ៣៣ | ព្រិន្ទបាលទោ | ស៊ីន | សារ៉ាន់ | អត្តលេខ ០៨២៩៧៨ បុគ្គលិកបញ្ជូនសារ អនុសេនាតូចដឹកជញ្ជូន វរសេនាតូច៥១៥ កងពលតូចថ្មើរជើងលេខ៥១ |
| ៣៤ | ព្រិន្ទបាលទោ | ឆិត | សេរីវឌ្ឍន៍ | អត្តលេខ ១៧៧៧៥០ យុទ្ធជន វរសេនាតូច៥២៤ កងពលតូចថ្មើរជើងលេខ៥២ |
| ៣៥ | ព្រិន្ទបាលទោ | ម៉ុ | ម៉ឺន | អត្តលេខ ២២៧០១០ យុទ្ធជន វរសេនាតូច៥២១ កងពលតូចថ្មើរជើងលេខ៥២ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៩១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង សមាសភាពក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា “ កម្ពុជា រ៉េ ” អាណត្តិទី៥

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា “ **កម្ពុជា រ៉េ** ”
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងជាប្រធាន និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ហៅកាត់ថា “ **កម្ពុជា រ៉េ** ” អាណត្តិទី ៥ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សៅ សីលម៉ា** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- | ឯកឧត្តម **អ៊ឹម ស៊ីថុល** | អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- | ឯកឧត្តម **ម៉ែន ពេជ្រសារី** | អគ្គនាយកបច្ចេកទេសនៃក្រសួងយុត្តិធម៌ | សមាជិក |
| ៤- | លោក **ហ៊ុយ ទ៉ាវថារ៉ូ** | អគ្គនាយក ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា | សមាជិក |
| ៥- | តំណាងនិយោជិករបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា | | សមាជិក |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ដូចមាត្រា ១ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៩២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង អគ្គនាយក
## នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រ៉េ " អាណត្តិទី៥

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " **កម្ពុជា រ៉េ** "
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ហ៊ុយ វ៉ាថារ៉ូ** បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គនាយក នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ហៅកាត់ថា " **កម្ពុជា រ៉េ** " អាណត្តិទី ៥

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ដូចមាត្រា ១ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៧២ សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយ និងរដ្ឋាករខេត្តត្បូងឃ្មុំ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការបង្កើតខេត្តត្បូងឃ្មុំ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ដែលជាអង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានការិយាល័យកណ្តាលប្រចាំនៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**ប្រការ ២.-**

សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានសាខាមួយចំនួនជាជំនួយការ។

**ប្រការ ៣.-**

សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ មានមុខងារ និងភារកិច្ចដូចតទៅ :

១. គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់ លើអង្គភាពគយនិងរដ្ឋាករ ដែលស្ថិតក្រោមនិវាទ និង/ឬ ស្ថិតក្នុងភូមិសាស្ត្រខេត្តត្បូងឃ្មុំ រាប់បញ្ចូលទាំងការិយាល័យគយនិងរដ្ឋាករតាមមូលដ្ឋាន ឬតាមបណ្តាទីស្នាក់ការគយនិងរដ្ឋាករត្រួតពិនិត្យច្រកទ្វារព្រំដែននានា ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួនតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

២. ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ព័ន្ធទាំងឡាយឱ្យយល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់ នៃទំនិញនាំចូល- នាំចេញ និងការទទួលខុសត្រូវចំពោះមុខច្បាប់ រាល់ពេលរកឃើញមានការចូលរួមគេចវេសកាតព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬដោយប្រយោល ការធ្វើចរាចរ ចែកចាយ សន្និធិទំនិញនាំចូល- នាំចេញដោយល្មើសនានាក្នុងមូលដ្ឋានអាជីវកម្មដ្ឋាន ឬរំលំនៅដ្ឋាននីមួយៗ។

៣. ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់ខេត្តត្បូងឃ្មុំលើទំនិញនាំចូល- នាំចេញដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬកំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា និងទទួលខុសត្រូវនូវនិរន្តរភាពចំណូលពន្ធអាករគយ ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន។

៤. ចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិអាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានាដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលតេលសិលាភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀត ដែលនឹងកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៥. សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសម្រេចឱ្យបាននូវភារកិច្ចដូចបានចែងក្នុងប្រការនេះ។

៦. អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្របតាមបទបញ្ញត្តិច្បាប់ជាធរមាន។

**ប្រការ ៤.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៤*

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- គ្រប់សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៦៤ សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋលើមុខទំនិញមួយចំនួន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ២៨១ សហវ.ប្រក.អគរ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឲ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០១២
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋ លើមុខទំនិញកម្ទេចឬចំណាំងឈើ (Wood in Chips or Particles) អាចម៍រណា (Sawdust) ព្រមទាំងកម្ទេចឈើ (Chipwood) ផ្សេងទៀតដែលមានលេខកូដសម្គាល់ ៤៤០១.២១.០០ ៤៤០១.២២.០០ ៤៤០១.៣១.០០ និង ៤៤០៤.២០.១០ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១២ ដែលផលិតឬកែច្នៃចេញពីឈើដាំក្នុងស្រុកដូចជា ដើមអាកាស្យា និងដើមប្រេងខ្យល់ ជាដើម។

អាករនាំចេញដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រាជាចំណូលនៃថវិកាប្រចាំខែរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងអនុគណនីចំណូលថវិកាលេខ ៧១១១ ហើយត្រូវកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់ចែង និងអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៣៩៣ ឧស.កក-ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ៦៧៥/១៤គ.វ.ក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីន ជីធាន (ខេមបូឌា) ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីន ជីធាន (ខេមបូឌា) (SHIN JITIAN (CAMBODIA) CO., LTD.) តំណាងដោយ លោក XIE, BO សញ្ជាតិចិន អាយុ៤៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E34571518 ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានអាសយដ្ឋានបច្ចុប្បន្ន៖ Zhejiang, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីន ជីធាន (ខេមបូឌា) "*
**ទីតាំងរោងចក្រ៖** *" ភូមិកណ្តាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រកា១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៣០៩/ឧស.ក/១៤/ប្រក

## ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-យោងលិខិតលេខ ៧៤១/១៤ គ.វ.ក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ី.ស៊ី.អេស សេរីនគរ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤

## <u>ស ម្រេ ច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ី.ស៊ី.អេស សេរីនគរ (C.C.S SEREYNOKOR CO., LTD.) តំណាងដោយ លោក BOONJAROEN MANOBURACHAILERT សញ្ជាតិថៃ អាយុ៧២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ Z458157 ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ មាន អាសយដ្ឋានបច្ចុប្បន្ន៖ អាគារលេខ១A ផ្លូវលំ ភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev4 Code** |
|---|---|
| -សម្ភារៈវេចខ្ចប់(ពីប្លាស្ទិក)(Plastic Package) | ២២២០ |
| -សម្ភារៈវេជ្ជសាស្ត្រ(ពីប្លាស្ទិក)(Plastic Injection) | ៣២៥០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រផលិតផលិតផលពីប្លាស្ទិក ស៊ី.ស៊ី.អេស សេរីនគរ"*
**ទីតាំងរោងចក្រ ៖** *"ភូមិខ្វារ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។ ៣៣៧

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូត ប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបិទភ្ជាប់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមប្រកាសស្តីពី សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០១៤

**ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៤០ ឧស.ក.ប្រក

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ៩៧៣/១៤គ.វ.ក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វូ គៀត ព្រីនធីង ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វូ គៀត ព្រីនធីង (FU KIET PRINTING CO., LTD.) តំណាងដោយ លោក LIAO, YU-HAO សញ្ជាតិចិន(តៃវ៉ាន់) អាយុ៣៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 21252 2334 ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន៖ Kaohsiung City, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC-Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់(បោះពុម្ព) | ១៣១៣ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23 211141 , Fax: 855 23 428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រពោះពុម្ពលើសម្លៀកបំពាក់ ហ៊ី គៀត ព្រីនធីង "*
**ទីតាំងរោងចក្រ៖** *" ភូមិព្រៃសាលា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចចូល ឬចាត់ឱ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរនៅខាងលើ និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ នៅមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឱ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ឱ្យច្បាស់លាស់ អំពីវត្ថុសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមប្រកាសស្តីពីសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ